ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

****

ឆ្នាំទី ៣ លេខ ៤២ ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

ក

មាតិកា

I- ទីស្តីការគណៈរដ្ឋមន្ត្រី

១—អនុក្រឹត្យ

១៦.១១.៩៥	អនុក្រឹត្យលេខ ៨១ អនក្រ.បក ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និង អង្គការសាធារណៈ[illegible]	២១១៨
១៦.១១.៩[illegible]	អនុក្រឹត្យលេខ ៨២ អនក្រ.បក ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ	២១២៨
២០.១១.៩៥	អនុក្រឹត្យលេខ ៨៣ អនក្រ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ	២១៥៣
២០.១១.៩៥	អនុក្រឹត្យលេខ ១៩៩ អនក្រ. ស្តីពីការតែងតាំងមន្ត្រី រាជការ	២១៥៧
២១.១១.៩៥	អនុក្រឹត្យលេខ ១២០ អនក្រ.តត ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ	២១៥៨
២២.១១.៩៥	អនុក្រឹត្យលេខ ១២១ អនក្រ.តត ស្តីពីការពន្យារពេលចូលនិវត្តន៍មន្ត្រី រាជការ	២១៥៩
២៣.១១.៩៥	អនុក្រឹត្យលេខ ១២២ អនក្រ.តត ស្តីពីការពន្យារពេលចូលនិវត្តន៍មន្ត្រី រាជការ	២១៦១

២—សេចក្តីសំរេច

១៧.១១.៩៥	សេចក្តីសំរេចលេខ ៧៨ សសរ ស្តីពីការប្រគល់ភារកិច្ចបណ្តោះអាសន្ន	២១៦២
២១.១១.៩៥	សេចក្តីសំរេចលេខ ៧៩ សសរ ស្តីពីការប្រគល់ភារកិច្ចបណ្តោះអាសន្ន	២១៦៣

II- ការងារបណ្ដាក្រសួង

១—ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

១៧.១១.៩៥ ប្រកាសលេខ ២០៤ សហវ ប្រក.ប ស្ដីពីការដាក់ឯកឧត្តម ជាវ ឡាវ ជាអតីតអនុរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុចូលនិវត្តន៍ ២១៦៤

២០.១១.៩៥ ប្រកាសលេខ ៣៨៧ ប្រកសហវ.ថ ស្ដីពីការបង្វែរឥណទាន ២១៦៥

២០.១១.៩៥ ប្រកាសលេខ ៣៨៩ ប្រកសហវ.ថ ស្ដីពីការបង្វែរឥណទាន ៦១៦៧

២—ទីស្ដីការរដ្ឋមន្ត្រីក្រសួងពត៌មាន

សេចក្ដីសំរេច

១៦.១១.៩៥ សេចក្ដីសំរេចលេខ ២៧៦/៩៥ ពម.សសរ ស្ដីពីការបង្កើតគណៈកម្មការសាងសង់ ២១៧០

ប្រកាស

១៧.១១.៩៥ ប្រកាសលេខ ២៧៨/៩៥ ពម.ប្រក អនុញ្ញាតអោយលោក លឹស ចិន្តា បើកអាជីវកម្មរោងពុម្ពដែលមានឈ្មោះ «វិចិត្រសិល្បៈ» ២១៧១

១៧.១១.៩៥ បកាសលេខ ២៧៩/៩៥ ពម.ប្រក ស្ដីពីការអនុញ្ញាតអោយបង្កើតស្ថានីយ៍ទូរទស្សន៍ប្រើខ្សែកាប ២១៧២

២១.១១.៩៥ ប្រកាសលេខ ២៨០/៩៥ ពម.ប្រក អនុញ្ញាតអោយទស្សនាវដ្ដី «ឆ្ពោះទៅមុខ» បោះពុម្ពផ្សាយ ដោយមានអ្នកស្រី ជូ ប៊ុនអេង ជាថៅកែហាងការផ្សាយ ២១៧៣

២១.១១.៩៥ ប្រកាសលេខ ២៨១/៩៥ ពម.ប្រក អនុញ្ញាតអោយបោះពុម្ពផ្សាយទស្សនាវដ្ដីឈ្មោះ «សុវណ្ណមច្ឆា» ដោយមាននាង សុក សុទ្ធី ជាថៅកែហាងការផ្សាយ ២១៧៥

២១.១១.៩៥ ប្រកាសលេខ ២៨២/៩៥ ពម.ប្រក អនុញ្ញាតអោយទស្សនាវដ្តី «យុវជន» បន្តបោះពុម្ពផ្សាយ ដោយមានលោក អ៊ុម សួស្តី ជាថាងហ្វាងការផ្សាយ ២១៧៦

២១.១១.៩៥ ប្រកាសលេខ ២៨៣/៩៥ ពម.ប្រក អនុញ្ញាតអោយកាសែត «អង្គរថ្មី» បោះពុម្ពផ្សាយឡើងវិញ ដោយមានលោកស៊ុំ តារា ជាថាងហ្វាងការផ្សាយ ២១៧៧

៣—ទីស្តីការរដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

ប្រកាស

២១.១១.៩៥ ប្រកាសលេខ ៧៦១ ប្រក.សក.ប ស្តីពីការប្រគល់ភារកិច្ចជូន មន្ត្រីរាជការ ២១៧៩

៤—ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

ប្រកាស

២១.១១.៩៥ ប្រកាសលេខ ២៨៥៦ អយក.ប្រក ស្តីពីការប្តូរឈ្មោះ វិទ្យាល័យ ៧ មករា ទៅជា «វិទ្យាល័យសម្តេចម៉ែ» ស្ថិតនៅក្នុងក្រុមហ៊ុនចំការកៅស៊ូជប់ ខេត្ត កំពង់ចាម ២១៨១

២១.១១.៩៥ ប្រកាសលេខ ២៨៥៧ អយក.ប្រក ស្តីពីការពង្រីកអនុវិទ្យាល័យអង្គរនាម ទៅជា វិទ្យាល័យ «អង្គរនាម» ក្នុងស្រុកត្រាំកក់ ខេត្តតាកែវ ២១៨២

៥—ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

ប្រកាស

១៧.១១.៩៥ ប្រកាសលេខ ៨២២ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ស៊ឹម គីមគិ ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនផលិត ទឹកកកដើម ២១៨៤

១៧.១១.៩៥ ប្រកាសលេខ ៨២៣ ផក.ប្រក អនុញ្ញាតអោយលោក លី ឃាង ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនផលិត ទឹកកកដើម ២១៨៤

១៧.១១.៨៥ ប្រកាសលេខ ៨២៤ ផក.ប្រក អនុញ្ញាតអោយលោក ឡឹក ឃៀង ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនផលិតទឹកកកដើម ២១៨៥

១៧.១១.៩៥	ប្រកាសលេខ៨២៥ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ខេង ឡេង ជនជាតិខ្មែរ បើកដំណើរការឧស្សាហកម្មផលិតទឹកបរិសុទ្ធ អាស៊ីតិច សញ្ញា «ផ្កាឈូក»	២១៨៥
១៧.១១.៩៥	ប្រកាសលេខ ៨២៦ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ម៉េង សុគុណវុឌ្ឍ ជនជាតិខ្មែរ បន្តដំណើរការឧស្សាហ កម្មតូចផលិតទឹកបរិសុទ្ធ សញ្ញា ប៉ិនគ្វិន (Penguin)	២១៨៦
១៧.១១.៩៥	ប្រកាសលេខ ៨២៧ ផក.ប្រកអនុញ្ញាតអោយលោក ឡាញ់ រោគ ជនជាតិខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៣០ សេះ	២១៨៦
១៧.១១.៩៥	ប្រកាសលេខ ៨២៨ ផក.ប្រក អនុញ្ញាតអោយលោក សាន់ មិត្ត ជនជាតិខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ	២១៨៧
១៧.១១.៩៥	ប្រកាសលេខ ៨២៩ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី រ៉ែម គីក ជនជាតិខ្មែរ បើកដំណើរការសិប្បកម្មផលិតទឹកត្រីសញ្ញា «ត្រីក្អែក»	២១៨៨
១៧.១១.៩៥	ប្រកាសលេខ ៨៣០ ផក.ប្រកអនុញ្ញាតអោយលោក លឹម សេង ជនជាតិខ្មែរ បន្តដំណើរការឡផលិតឥដ្ឋ ក្បឿង	២១៨៨
១៧.១១.៩៥	ប្រកាសលេខ ៨៣១ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ម៉េង ហៃ ជនជាតិខ្មែរ បន្តដំណើរការសិប្បកម្មកាត់ដេរ សំលៀកបំពាក់	២១៨៩

I-ទីស្តីការគណៈរដ្ឋមន្ត្រី

១—អនុក្រឹត្យ

រាជធានីភ្នំពេញ,ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

អនុក្រឹត្យ លេខ ៨១ អន ក្រ បក

ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋ

នៅតាមក្រសួង ខេត្ត—ក្រុង—ក្រុងស្វយ័ត—រាជធានីភ្នំពេញ និង

អង្គការសាធារណៈរដ្ឋបាល

* * *

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-យោងព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច ព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-យោងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣

-បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤

-តាមការចាំបាច់របស់រាជរដ្ឋាភិបាល

សំរេច

មាត្រា ១ : ត្រូវបានបង្កើតអោយមានការត្រួតពិនិត្យហិរញ្ញវត្ថុ ស្ថិតនៅក្រោមការគ្រប់គ្រង

របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ការត្រួតពិនិត្យហិរញ្ញវត្ថុមានមុខងារសំខាន់ក្នុងការត្រួតពិនិត្យជាមុននូវសេចក្ដីបំព្រួចចំណាយថវិកាជាតិ និង គណនីពិសេសនៅរតនាគារ ។ ម្យ៉ាងទៀត ការត្រួតពិនិត្យហិរញ្ញវត្ថុអាចជួយ ក្នុងការផ្ទៀងផ្ទាត់ពេលក្រោយនៅនឹងកន្លែង លើការអនុវត្តន៍ចំណាយសាធារណៈ ។ និយាយរួមការត្រួតពិនិត្យហិរញ្ញវត្ថុ មានប្រសិទ្ធភាពអនុវត្តខ្លឹមសារនៃអនុក្រឹត្យនេះ និង ស្របតាមច្បាប់បញ្ញត្តិទាំងឡាយជាធរមាន ។

មាត្រា ២ : ការត្រួតពិនិត្យហិរញ្ញវត្ថុអនុវត្តដោយអ្នកត្រួតពិនិត្យហិរញ្ញវត្ថុដែលចាត់ឡើងតាមប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៅរដ្ឋបាលកណ្ដាល និងអង្គភាពនានាក្នុងខេត្ត-ក្រុង ក្រុងស្វយ័ត-រាជធានីភ្នំពេញ និង នៅអង្គការសាធារណរដ្ឋបាល ។ ការរៀបចំត្រួតពិនិត្យហិរញ្ញវត្ថុ សំរេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ជំពូកទី ១

កម្មវត្ថុ និង ចរិត នៃការត្រួតពិនិត្យហិរញ្ញវត្ថុ

មាត្រា ៣ : គ្មានចំណាយជាសាធារណៈមួយក្នុងថវិកាជាតិឬ ក្នុង គណនីពិសេសរបស់រតនាគារអាចយល់ព្រម ឬ ទទួលអោយចាប់ផ្ដើមអនុវត្តបានដោយអាណាប័កដើមខ្សែ ឬ អាណាប័ក ផ្ទេរសិទ្ធិ បើគ្មានការស្នើសុំជាលាយល័ក្ខអក្សរ និង មានទិដ្ឋាការយល់ព្រមពីអ្នកត្រួតពិនិត្យហិរញ្ញវត្ថុទេនោះ ។

មាត្រា ៤ : ការត្រួតពិនិត្យហិរញ្ញវត្ថុ ពិនិត្យអំពីភាពត្រឹមត្រូវនៃការស្នើសុំចំណាយហើយការពិនិត្យនេះផ្អែក លើកត្តាដូចខាងក្រោម ÷

- កម្មវត្ថុនៃការចំណាយ
- បន្ទុកចំណាយនៃថវិកា ត្រឹមត្រូវតាមបទបញ្ញាផ្សាយចេញពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រភេទនៃការចំណាយសមស្របតាមការកំណត់នៃសៀវភៅថវិកាដែលមាន ចែងជាឥណទានថវិកា
- ភាពត្រឹមត្រូវក្នុងការវាយតំលៃនៃការចំណាយ
- ភាពទំនេរនៃឥណទាន
- ការអនុវត្តន៍ត្រឹមត្រូវទៅតាមបទបញ្ញត្តិច្បាប់ហិរញ្ញវត្ថុ ព្រះរាជក្រឹត្យព្រះរាជក្រម និងបទបញ្ញាផ្សេងៗ ជាធរមាន

-ការចំណាយ ត្រូវធ្វើអោយបានត្រឹមត្រូវទៅនឹងកិច្ចការរៀបចំនៃថវិកា

-ជាទូទៅ សំណុំរឿងទាំងអស់ត្រូវតែមានសក្ខីប័ត្រពន្យល់ ឬបញ្ជាក់ ទើបការត្រួតពិនិត្យ ហិរញ្ញវត្ថុមានលទ្ធភាពវាយតម្លៃបានអំពីសំណើចំណាយទាំងនោះ

-អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ទោះស្ថិតក្នុងករណីណាក៏ដោយ មិនត្រូវពង្រីកសិទ្ធិរបស់ខ្លួន គ្របសង្កត់ទៅលើបញ្ហាទាំងឡាយនៃ ចំណាយក្នុងកាលានុវត្តភាព ។

មាត្រា ៥ : អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ជាតំណាងស្របច្បាប់នៅក្នុងគណៈកម្មការទីផ្សារសាធារណៈ ។ ទីផ្សារសាធារណៈ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យដំបូងបង្អស់របស់អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ អំពីភាពទំនេរនៃឥណទានដែលត្រូវផ្តល់ ។ ទីផ្សារដែលបានសំរេចរួចហើយការត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវរក្សាឥណទានទុកផ្តល់ជូនស្មើតំលៃដែលបានគ្រោងសំរាប់ទូទាត់ ។ អ្នកត្រួតពិនិត្យហិរញ្ញវត្ថុតាមដានការអនុវត្តន៍របស់ទីផ្សារ ហើយធ្វើរបាយការណ៍អំពីលទ្ធផលការងារប្រចាំខែជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ជំពូកទី ២

របៀបរបបការងាររបស់អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ

មាត្រា ៦ : សំណើចំណាយត្រូវផ្ញើទៅអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ដោយអាណាប័កដើមខ្សែ ឬអាណាប័កតាមការប្រទានសិទ្ធិជាលក្ខណៈកិច្ចសន្យា ។ បន្ថែមលើសក្ខីប័ត្រចាំបាច់ សំណើចំណាយត្រូវមានភ្ជាប់នូវសលាកប័ត្រកត់ត្រាចំណាយថវិកាត្រួតពិនិត្យហិរញ្ញវត្ថុដែលបានបំពេញត្រឹមត្រូវ និងចុះហត្ថលេខាដោយអាណាប័ក ។ សលាកប័ត្រនេះ រៀបចំដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុហើយត្រូវមានបញ្ជាក់អំពីកម្មវត្ថុនៃការចំណាយ ការវាយតំលៃបន្ទុកចំណាយ ថវិកា និងចំណុចផ្សេងទៀតសំដៅសំរួលដល់ការងារត្រួតពិនិត្យ ។

មាត្រា ៧ : អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវប្រើប្រាស់រយៈពេល ០៣ ថ្ងៃ នៃថ្ងៃធ្វើការដើម្បីរៀបចំយោបល់របស់ខ្លួន ។ ផុតរយៈពេលនេះ ចាត់ទុកថាអ្នកត្រួតពិនិត្យ ហិរញ្ញវត្ថុយល់ព្រមដោយស្វ័យប្រវត្តិ ហើយការចំណាយត្រូវបានចាប់ផ្តើមអនុវត្ត ។ ប៉ុន្តែអ្នកត្រួត ពិនិត្យហិរញ្ញវត្ថុ អាចសុំធ្វើការបំភ្លឺ ផ្តល់ពត៌មានឬសេចក្តីបញ្ជាក់បន្ថែមបើយល់ថាជាការចាំបាច់ ។

មាត្រា ៨ : យោបល់របស់អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវធ្វើអោយបានសមហេតុសមផល ដោយសរសេរជាលាយល័ក្ខអក្សរ លើសលាកប័ត្រកត់ត្រាចំណាយថវិកា និងត្រួតពិនិត្យហិរញ្ញវត្ថុ តាមល័ក្ខខ័ណ្ឌដូចតទៅ ៖

១-បើសំណុំរឿងស្នើសុំចំណាយ គ្មានបង្ហាញអំពីការខុសឆ្គងអ្វីទេ អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបញ្ជាក់ការចំណាយដោយចុះលើសលាកប័ត្រកត់ត្រាចំណាយថវិកា និង ត្រួតពិនិត្យ ហិរញ្ញវត្ថុ នូវរូបមន្ត «ទិដ្ឋាការយល់ព្រម» រួចចុះហត្ថលេខា និងចុះកាលបរិច្ឆេទ ។

២-ករណីពិនិត្យឃើញមានការខុសឆ្គង អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវសរសេរជាលាយល័ក្ខអក្សរនៅលើសលាកប័ត្រអំពីការខ្វះខាតទាំងនោះ ហើយធ្វើត្រឡប់ទៅអ្នកទទួលបន្ទុកចំណាយនៃអាណាប័កដើមវិញ ។ ក្នុងករណីនេះ ត្រូវហាមការអនុវត្តន៍ចំណាយហើយ ចាំបាច់អោយឆ្លើយអំពីការសង្កេតរបស់អ្នកត្រួតពិនិត្យហិរញ្ញវត្ថុដោយធ្វើការពន្យល់ និងផ្តល់សេចក្តីបញ្ជាក់អោយបានគ្រប់គ្រាន់តាមសំណើ ។

៣-បើការឆ្លើយបញ្ជាក់នោះ [illegible] បានគាល់ចំណុចខ្វះខាតដែលមាននោះ អ្នកត្រួត ពិនិត្យហិរញ្ញវត្ថុ ត្រូវអនុវត្តតាមបែបបទដូចមានចែងក្នុងល័ក្ខខ័ណ្ឌទី ១ ខាងលើ ។

៤-ផ្ទុយទៅវិញ ការយល់ទាស់របស់អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវរក្សាទុកហើយ កិច្ចសន្យាចំណាយមិនត្រូវបានចុះទិដ្ឋាការទេ ។ ករណីមានការទាមទារពីអាណាប័កដើម្បីរក្សាសំណើចំណាយ ទោះបីឃើញមានភាពមិនប្រក្រតីក៏ដោយ នោះអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបញ្ជូន សំណុំរឿង ទៅអ្នកទទួលបន្ទុកចំណាយនៃអាណាប័ក ហើយព្រមជាមួយនោះ ត្រូវធ្វើរបាយការណ៍បញ្ជាក់អំពីមូលហេតុពិទាស់ផ្ញើជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យសំរេចចុងក្រោយជាលាយល័ក្ខអក្សរក្នុងរយៈពេលសមស្រប ។

ក្នុងរយៈពេលនេះ គ្មានអង្គភាពណាមួយដែលអាចរំលងទិដ្ឋាការរបស់អ្នកត្រួតពិនិត្យហិរញ្ញ វត្ថុបានទេ ក្រៅពីសេចក្តីសំរេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

មាត្រា ៩ : រាល់បញ្ជាចំណាយមុននឹងបញ្ជូនទៅរតនាគារ ក្រៅពីសក្ខីប័ត្រធម្មតាត្រូវតែមានភ្ជាប់ជាមួយ នូវសំណើសុំចំណាយដែលមានចុះទិដ្ឋាការរបស់អ្នកត្រួតពិនិត្យ

ហិរញ្ញវត្ថុ ឬ សេចក្ដីបញ្ជាក់ការ តាមជានរបៀបរបបចុះកិច្ចសន្យា ។ ធនាគារត្រូវផ្ទៀងផ្ទាត់ការបំពេញបែបបទអោយបាន សមស្របតាមបទបញ្ញត្តិទាំងឡាយនៃជំពូកទី ៣ ខាងក្រោយនេះ ។

បញ្ជាចំណាយដែលមិន បានបំពេញតាម ល័ក្ខខ័ណ្ឌខាងលើនេះ នឹងគ្មានតំលៃចំពោះធនាគារទេ ហើយត្រូវបញ្ជូនត្រឡប់ទៅវិញដើម្បីធ្វើឯកសារភ្ជាប់គ្រប់គ្រាន់ទើបទទួលស្គាល់និង អនុវត្ត ។ គណនេយ្យករដែលព្រមទទួលអនុវត្តបញ្ជាចំណាយនេះទទួលខុសត្រូវជាបុគ្គល និង ប្រាក់កាស ។

ជំពូកទី ៣

បែបបទចុះកិច្ចសន្យាចំណាយ

មាត្រា ១០ : ស្របតាមបទបញ្ញត្តិនៃមាត្រាទី ៣ ខាងដើម កិច្ចសន្យាចំណាយ ត្រូវឆ្លងចុះទិដ្ឋាការជាមុនពីអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ។ ទិដ្ឋាការនេះ ត្រូវបានផ្ដល់ដោយផ្ទាល់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុចំពោះចំណាយ ទាំងឡាយដែលមានទឹកប្រាក់ស្មើនឹងទឹកប្រាក់កំណត់ដោយអនុក្រឹត្យ ។ ប៉ុន្តែចំណាយទាំង ឡាយដែលមានចែងនៅផ្នែកទី ១ ខាងក្រោមនេះ អាចលើកលែងនូវការចុះទិដ្ឋាការបាន ហើយអាណាប័ក អាចសុំចុះកិច្ច សន្យាទាំងស្រុង ឬ កិច្ចសន្យាជាបណ្ដោះអាសន្ន ។

ជំពូកទី ១

អំពីការលើកលែងទិដ្ឋាការ

មាត្រា ១១ : ត្រូវបានលើកលែងទិដ្ឋាការដែលមានចែងក្នុងមាត្រាទី ៣ ខាងដើម :

១– ចំណាយមានលក្ខណៈមិនទៀងទាត់ដែលមានទឹកប្រាក់កំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ :

– ចាត់ទុកជាចំណាយមិនទៀងទាត់ គឺចំណាយមិនប្រក្រតី ហើយមិនអាចប្រមូលផ្ដុំទៅលើអាបណាសញ្ញាការងារការផ្គត់ផ្គង់ ឬ សេវាកម្ម ។

– ចំណាយទាំងនេះ ត្រូវបានកត់ត្រាទុកដោយអ្នកត្រួតពិនិត្យហិរញ្ញវត្ថុក្រោយពីបានចុះកិច្ចសន្យា ។

២– ចំណាយផ្ដល់តាមបុរេប្រទាន :

ទិដ្ឋាការរបស់អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ចាំបាច់ត្រូវចុះនៅពេលបើកប្រាក់ដើម្បីសំរួលដល់ថវិកាចំណាយ និងគិតគូរប្រាក់បុរេប្រទានអោយត្រឹមត្រូវតាម

ចំនួនដែលបានយល់ព្រម ។

៣- ចំណាយដែលទាក់ទងករណីដោយឡែក ប៉ះពាល់ដល់វិស័យយោធា- សន្តិសុខជាតិ ហើយត្រូវរក្សាសម្ងាត់ ។ ចំណាយប្រភេទនេះ ត្រូវធ្លងតាមបែបបទពិសេសដែលចែងដោយអនុក្រឹត្យ ។

ផ្នែកទី ២

ការចុះកិច្ចសន្យាទាំងស្រុង

មាត្រា ១២ : អាណាប័កដើមខ្សែ ឬ ផ្ទេរសិទ្ធិអាចសុំចុះកិច្ចសន្យាទាំងស្រុង ចំពោះចំណាយដែលមានលក្ខណៈជាប្រក្រតីនៅដើម ឬចន្លោះនៃការគ្រប់គ្រង ។ ទិដ្ឋាការនៃកិច្ចសន្យាទាំងស្រុង យល់ព្រមដោយអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ មានតំលៃស្មើទឹកប្រាក់សរុបនៃកិច្ចសន្យា ។ ចំណាយទាំងឡាយដែលស្ថិតនៅក្នុងបន្ទុកចំណាយថវិកាតែមួយ អាណាប័កមិនចាំបាច់ឆ្លងទិដ្ឋាការរបស់អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ចំពោះកិច្ចសន្យាលំអិត នៃចំណាយនីមួយៗ ឡើយ ។

មាត្រា ១៣ : នីតិវិធីនៃកិច្ចសន្យាទាំងស្រុងអនុវត្តជាអាទិ៍ចំពោះចំណាយដូចតទៅ :

១- ចំណាយលើបៀវត្ស និង ប្រាក់បំណាច់បន្ទាប់បន្សំ

២- ចំណាយមានលក្ខណៈជាប្រក្រតីហើយបានចុះកិច្ចសន្យាតាមសេចក្តីសំរេចពីមុនដរាបណាពុំទាន់មានសេចក្តីសំរេចថ្មីមកជំនួស ។

៣- ប្រាក់ឈ្នួល

៤- ប្រាក់ឧបត្ថម្ភសំរាប់ដំណើរការអង្គការសាធារណៈរដ្ឋបាល

៥- ចំណាយសំរាប់សងបំណុលសាធារណៈ

៦- ការបង់វិភាគទានអោយអង្គការអន្តរជាតិ

៧- ចំណាយដែលត្រូវផ្តល់ ក្នុងក្របខ័ណ្ឌផ្គត់ផ្គង់ទីផ្សារសាធារណៈ ឬ ក្នុងក្របខណ្ឌ័អោយខ្ចីមុន តាមការវាយតំលៃសាច់ការដែលធ្វើបានហើយមានការយល់ព្រមពីគណៈកម្មការមានសមត្ថកិច្ច និងសាមុីស្ថាប័នគ្រប់គ្រង ។

មាត្រា ១៤ : រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អាចបន្ថែមប្រភេទចំណាយផ្សេងទៀតដើម្បីអោយ បានសមស្រប តាមនីតិវិធីនៃកិច្ចសន្យាទាំងស្រុង ។

ផ្នែកទី ៣

ការចុះកិច្ចសន្យាបណ្ដោះអាសន្ន

មាត្រា ១៥ : អាណាប័កដើមខ្សែ ឬអាណាប័កផ្ទេរសិទ្ធិ អាចសុំចុះកិច្ចសន្យាបណ្ដោះអាសន្ន ចំពោះ ចំណាយក្រៅពីចំណាយដែលបានចែងក្នុងផ្នែកទី ១ និងទី ២ ខាងលើ ជាពិសេស :

១- ចំណាយលើសំភារៈ និង ការគ្រប់គ្រងរដ្ឋបាល

២- ចំណាយក្នុងការសងថ្លៃឈ្នួល

៣- ចំណាយសំរាប់អន្តរាគមន៍សាធារណៈក្នុងវិស័យសេដ្ឋកិច្ចសង្គមកិច្ច វប្បធម៌ ។

មាត្រា ១៦ : កិច្ចសន្យាបណ្ដោះអាសន្ន អនុញ្ញាតអោយអាណាប័កសុំតាមរយៈអ្នកត្រួតពិនិត្យហិរញ្ញវត្ថុក្នុង ខ្ទង់ថវិកានីមួយ ។ ដើម្បីចុះកិច្ចសន្យាមួយចំណែកនៃឥណទាន កំណត់ដោយច្បាប់ហិរញ្ញវត្ថុជាគោលការណ៍ស្មើ ១/៤ នៃថវិកាផ្តល់ប្រចាំឆ្នាំ ។ ចំនួននេះអាចបន្ថែមឬបន្ថយ បានដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅតាមប្រភេទចំណាយនិងស្ថានភាពសាច់ប្រាក់របស់រដ្ឋ ។

មាត្រា ១៧ : សំណើដំបូងនៃកិច្ចសន្យាបណ្ដោះអាសន្ន អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវតែផ្តល់ទិដ្ឋាការជូន ទោះបីអាណាប័កមិនបានភ្ជាប់មកជាមួយនូវសក្ខីប័ត្រគ្រប់គ្រាន់ក៏ដោយ ។

សំណើបន្ទាប់ នៃកិច្ចសន្យាបណ្ដោះអាសន្ន ត្រូវភ្ជាប់មកជាមួយ នូវសក្ខីប័ត្រនៃសំណើលើកនេះនិងសំណើលើកមុន ហើយត្រូវបានចុះទិដ្ឋាការជូនត្រឹមចំនួនទឹកប្រាក់ដែលមានសក្ខីប័ត្រប៉ុណ្ណោះ សក្ខីប័ត្រទាក់ទងដល់កិច្ចសន្យាបណ្ដោះអាសន្នចុងក្រោយ ត្រូវផ្តល់អោយអ្នកត្រួតពិនិត្យហិរញ្ញវត្ថុមុនពេលបញ្ចប់ការគ្រប់គ្រង ។

មាត្រា ១៨ : ការពិនិត្យសក្ខីប័ត្រនៃកិច្ចសន្យាបណ្ដោះអាសន្នរបស់អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ បើសង្កេត ឃើញមានចំណុចដូចចែងក្នុងមាត្រា៨ខាងដើម អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវកត់ត្រាសេចក្តីសង្កេតទាំងនោះ ផ្ញើទៅអាណាប័កក្នុងរយៈពេលដូចមានចែងក្នុងមាត្រា ៧ ខាងដើម ។

សេចក្តីសង្កេតទាំងអស់នៃកិច្ចសន្យាបណ្ដោះអាសន្ន ជាកម្មវត្ថុរបស់អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវចងក្រងជាសេចក្តីរាយការណ៍សរុបក្នុងរយៈពេល២ខែម្តងផ្ញើ

ទៅជូនរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធ្វើការពិភាក្សាជាមួយអាណាប័កសាមី អំពីវិធានការដែលត្រូវដោះស្រាយ ដើម្បីកែលំអការខុសឆ្គងដែលមាន ដែលបង្ហាញអោយឃើញថា បានអនុវត្តតាមបែបបទនៃកិច្ចសន្យាបណ្តោះអាសន្ន ។

ផ្នែកទី៤

ការចុះកិច្ចសន្យាបន្ថែម និង លុបកិច្ចសន្យាចំណាយ

មាត្រា ១៩ : បើចង់បន្ថែម ឬបន្ថយចំណាយដែលបានចុះកិច្ចសន្យាពីមុនរួចហើយ ត្រូវធ្វើតាមបែបបទនៃ ការចុះកិច្ចសន្យាបន្ថែម ឬ លុបកិច្ចសន្យាចំណាយ ។ សំណើចុះកិច្ចសន្យា ឬលុបកិច្ច សន្យាត្រូវតែឆ្លងកាត់អ្នកត្រួតពិនិត្យហិរញ្ញវត្ថុដោយមានភ្ជាប់ជាមួយនូវលិខិតបញ្ជាក់ និង លិខិតយោងចាំបាច់ ។

ផ្នែកទី ៥

រយៈពេលចុះកិច្ចសន្យាចំណាយ

មាត្រា ២០ : ទិវាការចុះកិច្ចសន្យាចំណាយ ត្រូវបញ្ចប់នៅថ្ងៃទី ១០ ខែ ធ្នូ នៃឆ្នាំនីមួយ ។ លើកលែងមានករណីចាំបាច់ដោយមានសេចក្តីសមស្រប ទទួលស្គាល់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ជំពូកទី ៤

អំពីគណនេយ្យចំណាយចុះកិច្ចសន្យា

មាត្រា ២១ : អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវរួមចំណែកធានាជាមួយផ្នែកទទួលបន្ទុកចំណាយនៃអាណាប័ក ដើមខ្សែ និង អាណាប័កតាមការប្រទានសិទ្ធិ អំពីការខុសគ្នាក្នុងការចុះបញ្ជីគណនេយ្យ កិច្ចសន្យាចំណាយនិងតាមដានការប្រើប្រាស់ឥណទាន ។ របាយការណ៍ត្រូវធ្វើឡើងប្រចាំខែ ដើម្បីផ្ទៀងផ្ទាត់អំពីកិច្ចសន្យានិងការប្រើប្រាស់របស់អាណាប័ក ប្រៀបធៀបជាមួយបញ្ជីអនុវត្តចំណាយរបស់រតនាគារ ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាអ្នកកំណត់អំពីទម្រង់ និង លក្ខខណ្ឌនៃការចុះបញ្ជីគណនេយ្យ ។

ជំពូកទី ៥

អំពីការត្រួតពិនិត្យក្រោយពេលអនុវត្តចំណាយ ដោយអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ

មាត្រា ២២ : ក្រោយពេលអនុវត្តចំណាយ អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ មាននីតិសម្បទាក្នុងការរកឃើញតាមគ្រប់រូបភាពស្របច្បាប់ដែលយល់ថាចាំបាច់ នូវចំណាយថវិកាដែលបានធ្វើឡើងដោយមិនត្រឹមត្រូវ : សេវាកម្មការរៀបចំគំរោង ការទិញសំភារៈ ។ល។ ដើម្បីនឹងសំរេចក្នុងរឿងនេះ ភ្នាក់ងារត្រួតពិនិត្យហិរញ្ញវត្ថុ មានសិទ្ធិចូលដោយគ្មានជូនដំណឹងជាមុន តាមបញ្ជាបេសកកម្ម ចេញអោយដោយរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទៅកាន់ក្រសួង រដ្ឋលេខាធិការដ្ឋាន និង គ្រប់ខេត្ត–ក្រុង–ក្រុងស្វយ័ត ព្រមទាំងអង្គការរដ្ឋបាលសាធារណៈនានាដែលមានភារកិច្ច រាយការណ៍លំអិតនៃការណ៍អនុវត្តន៍ចំណាយ ។ អ្នកត្រួតពិនិត្យហិរញ្ញវត្ថុត្រូវធ្វើរបាយការណ៍ផ្ញើជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អំពីលក្ខណៈចំណាយដែលបានអនុវត្តរួចហើយ ។ ការខុសឆ្គងដែលមានក្នុងពេលអនុវត្ត និង ភាពខុសគ្នាដែលដកស្រង់ បានពីបញ្ជីកាតណនេយ្យជាសមត្ថកិច្ចដោះស្រាយរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងសំណើដាក់វិន័យដោយអនុលោមតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃ ព្រះរាជាណាចក្រកម្ពុជា ។ ក្រោយទទួលបានយោបល់សំរេច ពីគណៈរដ្ឋមន្ត្រីការអនុវត្តន៍ វិន័យខាងរដ្ឋបាល ឬ ប្តឹងទៅតុលាការត្រូវធ្វើទៅតាមករណីហេតុ ។

ជំពូកទី ៦

ចេនបញ្ញត្តិផ្សេង ៗ

មាត្រា ២៣ : អ្នកត្រួតពិនិត្យហិរញ្ញវត្ថុចូលរួមរាល់កិច្ចការរៀបចំថវិកានិងការកសាងច្បាប់ស្តីពីហិរញ្ញវត្ថុនិងប្រព័ន្ធហិរញ្ញវត្ថុ ។ អនុក្រឹត្យស្តីពីការអនុវត្តន៍ឥណទានតាមជំពូកនៃច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំនីមួយ ៗ ប្រកាសស្តីពីការបែងចែកឥណទានផ្ទៃក្នុងជំពូកតាមប្រការកថាខ័ណ្ឌវាក្យខ័ណ្ឌជូនបណ្តាក្រសួង រដ្ឋលេខា ធិការដ្ឋាន អភិបាលគ្រប់ខេត្ត–ក្រុង ត្រូវប្រគល់ជូនអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ។

មាត្រា ២៤ : ពាក្យស្នើសុំបង្វែរចំណាយ ផ្នែកផ្ទៃក្នុងនៃថវិកាឬដកចេញពីជំពូកចំណាយមិនបានគ្រោងទុក ត្រូវតែមានចុះទិដ្ឋាការរបស់ អ្នកត្រួតពិនិត្យហិរញ្ញវត្ថុមុនឆ្លង

ការពិនិត្យតាមដានការអនុវត្តន៍ថវិកា របស់អាយកដ្ឋានជំនាញនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ពាក្យស្នើសុំត្រូវតែមានបញ្ជាក់អំពី :

–សារៈប្រយោជន៍ពិតប្រាកដនៃចំណាយថ្មីដែលត្រូវស៊ុំ

–មូលហេតុនៃការខ្វះឥណទានដែលត្រូវទទួលបន្ទុកត្រូវចំណាយ

–ហេតុផលបញ្ជាក់អំពីការសល់ទឹកប្រាក់ក្នុងខ្ទង់ដែលត្រូវផេក

–ភាពពិតប្រាកដនៃទឹកប្រាក់ដែលនៅសល់

អនុក្រឹត្យ និង ប្រកាសស្ដីពីការផ្ទេរឥណទាន ត្រូវប្រគល់មួយច្បាប់ជូនអ្នកត្រួតពិនិត្យហិរញ្ញវត្ថុជាចាំបាច់ ។

មាត្រា ២៥ : បញ្ជារផ្ទេយ្យបុរេប្រទាន ប្រកាសនិងបទបញ្ញត្តិទាំងឡាយស្ដីពីបុរេប្រទាន និង សំណើដំបូងនូវប្រាក់បុរេប្រទានត្រូវឆ្លងទិដ្ឋាការអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ។ ប្រកាសស្ដីពីការតែងតាំង រដ្ឋទេយ្យករ ត្រូវប្រគល់មួយច្បាប់ជូនអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ។

មាត្រា ២៦ : រាល់កិច្ចប្រជុំការងាររបស់គណៈកម្មការអន្តរាល អំពីបញ្ហាសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវជូនដំណឹង ទៅអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ។ អ្នកត្រួតពិនិត្យហិរញ្ញវត្ថុអាចចូលរួម និងសំដែងយោបល់លើ សេចក្ដីសំរេចទាំងឡាយណាដែលមានការប៉ះពាល់ដល់ហិរញ្ញវត្ថុសាធារណៈ ។

មាត្រា ២៧ : គ្មានករណីណាមួយ ដែលទិដ្ឋាការរបស់អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ អាចជួយសំរាលបានការទទួលខុសត្រូវផ្ទាល់ របស់អាណាប័កចំពោះកំហុសក្នុងការគ្រប់គ្រង ដែលមានចែងនិងហាមក្នុង ច្បាប់និងបទបញ្ញត្តិជាធរមាន ។ សំណើដាក់វិន័យអ្នកត្រួតពិនិត្យហិរញ្ញវត្ថុផ្អែកតាមទស្សនៈកាតព្វកិច្ចនៃវិជ្ជាជីវៈ ត្រូវអនុលោមតាមច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២៨ : អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ចាំបាច់ត្រូវចូលរួមយោបល់លើសេចក្ដីព្រាងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស កិច្ចសន្យា ឬសេចក្ដីសំរេចដែលមានលក្ខណៈជាបទបញ្ជា និង មានផលប៉ះពាល់ដល់វិស័យហិរញ្ញវត្ថុ ។

មាត្រា ២៩ : រៀងរាល់ឆ្នាំ អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវធ្វើរបាយការណ៍សរុបអំពីការអនុវត្តន៍ថវិកាឆ្នាំកន្លងទៅ ដោយមានបញ្ជាក់អំពីលទ្ធផលនៃការត្រួតពិនិត្យ និង លើក

សំណួមពរកែលំអការអនុវត្តន៍ថវិកានៃឆ្នាំបន្ត ។

របាយការណ៍នេះ ត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ នៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ បន្ទាប់នៃឆ្នាំគ្រួតពិនិត្យ ។

មាត្រា ៣០ : រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំជាក់ស្តែងជាលក្ខណៈរដ្ឋបាល ដើម្បីសំរេច អោយបានជាបន្តបន្ទាប់នូវវិធានការនេះ ។

មាត្រា ៣១ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី គ្រប់ក្រសួង រដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋាន អភិបាល គ្រប់ខេត្ត–ក្រុង និង គ្រប់អាណាប័កដើមខ្សែ ឬ ផ្ទេរសិទ្ធិត្រូវទទួលអនុវត្តអនុក្រឹត្យ នេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណប្ញទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

អនុក្រឹត្យ លេខ ៨២ អនក្រ.បក

ស្តីពីចនបញ្ញានូនៅ នៃគណនេយ្យសាធារណៈ

* * *

រាជរដ្ឋាភិបាល

–បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

–យោងព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

–យោងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

–បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣

-បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១ នស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤

-តាមការចាំបាច់របស់រាជរដ្ឋាភិបាល

សំរេច

មាត្រា ១ : អនុក្រឹត្យនេះកំណត់នូវវិធានទាំងឡាយ សំរាប់អនុវត្តកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និង គណនេយ្យដែលជាលទ្ធផលនៃកិច្ចប្រតិបត្តិការថវិការដ្ឋ ។

កិច្ចប្រតិបត្តិការទាំងនេះ ជាភារៈរបស់អាណាប័កនិងគណនេយ្យករសាធារណៈ ។

កិច្ចប្រតិបត្តិការនេះ ពាក់ព័ន្ធអំពីចំណូល ចំណាយ កិច្ចប្រតិបត្តិការរតនវត្ថុ និង បីតិកភ័ណ្ឌរបស់រដ្ឋ ។

កិច្ចប្រតិបត្តិការនេះ ត្រូវបានឈាតគ្រងនៅក្នុងគណនេយ្យករទាំងឡាយ ដែលបង្កើតឡើងទៅ តាមបទដ្ឋានទូទៅ ហើយត្រូវស្ថិតនៅ ក្រោមការត្រួតពិនិត្យ នៃអាជ្ញាធរដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

ភាគ ១

ថវិការដ្ឋ

មាត្រា ២ : ថវិកាគឺជាកិច្ចការដែលព្យាករ និង អនុញ្ញាតចំណូល និង ចំណាយរបស់រដ្ឋ ។

ថវិកាត្រូវបាន បង្កើត ស្នើឡើង បញ្ជប់ និង ប្រតិបត្តិដោយត្រឹមត្រូវទៅតាមច្បាប់ហិរញ្ញវត្ថុ និង ប្រព័ន្ធថវិកា ។ លេខតាដែលសំដែងគណនីថវិកាត្រូវបញ្ជប់ អនុម័ត និងផ្ទៀងផ្ទាត់ក្នុងលក្ខណៈដូចគ្នា ។

ភាគ II

អាណាប័ក គណនេយ្យករសាធារណៈនិងរដ្ឋគណនេយ្យករ

ជំពូកទី ១

អាណាប័ក

មាត្រា ៣ : អាណាប័កបញ្ជាប្រតិបត្តិចំណូល និង បញ្ជាចំណាយដូចមានចែងក្នុងភាគ ពេខាងក្រោម នេះ ។ ចំពោះបញ្ហានេះ អាណាប័កពិនិត្យអនុវត្តសិទ្ធិទាំងឡាយរបស់រដ្ឋ

ជំពូកចំណូលសន្សំ និងជំពូកចំណាយ ។

មាត្រា ៤ : អាណាប័កអាចជាអាណាប័កដើមខ្សែ ឬ អាណាប័កតាមការប្រទាន សិទ្ធិហើយអាច ប្រគល់សិទ្ធិអំណាចរបស់ខ្លួន ឬ រកអ្នកជំនួសក្នុងករណីអាណាប័កអវត្តមាន ឬ មានធុរៈ ។

អាណាប័កដើមខ្សែ ព្រមទាំងអាណាប័កតាមការប្រទានសិទ្ធ ឬ អ្នក ជំនួសត្រូវបាន តែងតាំងអមគណនេយ្យករមុខការខាងចំណូល និង ចំណាយដែល ត្រូវបានទទួល បញ្ជាអោយប្រតិបត្តិដោយអាណាប័កទាំងនោះ ។

មាត្រា ៥ : រដ្ឋមន្ត្រីគឺជាអាណាប័កដើមខ្សែនៃចំណូល និង ចំណាយថវិកាទូទៅរបស់រដ្ឋ និង គណនីពិសេសរបស់រតនាគារ ។ បទបញ្ជាគណនេយ្យរបស់ក្រសួងនានា ត្រូវបាន ជ្រើសតាំងឡើងនូវប្រភេទមន្ត្រីរាជការដែលអាចទទួលសិទ្ធិប្រទាន ឬ ជំនួស អាណាប័កដើមខ្សែក្នុងករណីអវត្តមាន ឬ មានធុរៈ ។

មាត្រា ៦ : អភិបាលខេត្ត–ក្រុង គឺជាអាណាប័កតាមការប្រទាន សិទ្ធិសំរាប់ចំណាយគ្រប់គ្រង រដ្ឋបាលស៊ីវិលលើមណ្ឌលទឹកដីខេត្ត–ក្រុង របស់ខ្លួនក្នុងក្របខ័ណ្ឌ « សិទ្ធិប្រទាន នៃឥណទាន » ដែលធ្វើឡើងដោយអាណាប័កដើមខ្សែ ។

មាត្រា ៧ : អាណាប័ក ចេញដីកាចំណូលសំរាប់ធានាការប្រមូលឥណទេយ្យរបស់រដ្ឋ ។ អាណា ប័ក បញ្ជូនដីកាចំណូលទាំងនេះទៅគណនេយ្យករសាធារណៈដែលទទួល បន្ទុក ការប្រមូល ។

មាត្រា ៨ : អាណាប័កចេញដីកាចំណាយ ដោយភ្ជាប់ជាមួយយុត្តិកម្មចាំបាច់ជូនទៅគណ នេយ្យករសាធា រណៈមុខការនៃការចំណាយ ។ នៅពេលដែលគណនេយ្យករ ព្យួរទុកការទូទាត់ចំណាយណាមួយស្របតាមមាត្រា ៥៩ ខាងក្រោយនេះ អាណាប័កអាចបង្ខំជាលាយលក្ខអក្សរដោយ ផ្អែកតាមមាត្រា ៦១ ខាងក្រោម អោយគណនេយ្យករធ្វើការទូទាត់ក្រោមការទទួលខុសត្រូវរបស់ខ្លួន ។

មាត្រា ៩ : ដីកាទាំងឡាយដែលធ្វើឡើងដោយអាណាប័ក ត្រូវបានសំដែងនៅក្នុងគណៈ នេយ្យចុះបញ្ជីកា តាមវិធានទូទៅដែលបានកំណត់ដោយរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ១០ : អាណាប័កជាអ្នកទទួលខុសត្រូវលើសេចក្ដីបញ្ជាក់ដែលខ្លួនបានចេញ ។

មាត្រា ១១ : ដោយមូលហេតុណាមួយក្នុងការអនុវត្តន៍មុខការរបស់ខ្លួន អាណាប័កត្រូវទទួលការខុសត្រូវដែលចែងដោយនីតិកម្មជាធរមាន ។ ការទទួលខុសត្រូវនេះ អាចដាក់វិន័យព្រហ្មទណ្ឌ ឬ រដ្ឋប្បវេណី ។

ជំពូកទី ២

គណនេយ្យករសាធារណៈ

មាត្រា ១២ : គណនេយ្យករសាធារណៈជាអ្នកទទួលបន្ទុក ÷

–ការទទួលខុសត្រូវ និង ប្រមូលចំណូល ដែលអាណាប័កបានប្រគល់អោយប្រមូលគណនេយ្យដែលសង្កេតឃើញតាមកិច្ចសន្យា មូលប័ត្រកម្មសិទ្ធិ ឬ មូលប័ត្រផ្សេងៗទៀត ដែលគណនេយ្យករត្រូវបានរក្សាទុកដាក់ ព្រមទាំងបញ្ចូលក្នុងបញ្ជី នូវប្រាក់ពន្ធដារបង់ផលដៃ និង ចំណូលគ្រប់ប្រភេទទាំងអស់ដែលរដ្ឋមាននីតិសម្បទាទទួល

–ទូទាត់ចំណាយតាមបញ្ជាអាណាប័កដែលនៅអមជាមួយ

–ការពារ និង រក្សាទុកនូវមូលនិធិ តម្លៃនានារបស់រដ្ឋ និង គ្រឹះស្ថានសាធារណៈផ្សេងៗ ទៀត

–កាន់កាប់មូលនិធិ និង ចលនាគណនីប្រាក់ទំនេរ

–រក្សាទុកដាក់លិខិតយុត្តិកម្មនៃកិច្ចប្រតិបត្តិការ និង ឯកសារគណនេយ្យ

–កាន់គណនេយ្យតាមដំណែងដែលខ្លួនដឹកនាំ

មាត្រា ១៣ : គណនេយ្យករសាធារណៈ មានភារកិច្ច ÷

A - ក្នុងវិស័យចំណូល ត្រួតពិនិត្យភាពត្រឹមត្រូវនៃដីកាចំណូល

B - ក្នុងវិស័យចំណាយ ត្រួតពិនិត្យ :

–លក្ខណៈសម្បត្តិរបស់អាណាប័ក ឬ អាណាប័កតាមការប្រទានសិទ្ធិ

–សំណល់ទំនេរនៃឥណទាន

–ការកំណត់ត្រឹមត្រូវពិតប្រាកដនូវចំណាយតាមជំពូកដែលពាក់ព័ន្ធដល់របធាតុ និងមុខសញ្ញារបស់វា

–ការបញ្ជាក់ត្រឹមត្រូវអំពីសេវាដែលបានធ្វើហើយ និង ភាពប្រាកដប្រជានៃគណនា ជំរះឥណនេយ្យ

–មានការបញ្ជាក់ទិដ្ឋាការរបស់អភិបាលហិរញ្ញវត្ថុលើកិច្ចសន្យា និង អាណត្តិ

–ផលិតកម្មនៃយុត្តិកម្មគណនេយ្យ

–អនុវត្តវិធានបទបញ្ជា ស្តីពីអាជ្ញាយុកាល និង ប្រាសចាកសិទ្ធិនៃគណនេយ្យ

C - ក្នុងវិស័យបិតិកភ័ណ្ឌ ត្រួតពិនិត្យ

–ការរក្សានូវសិទ្ធិ បុព្វសិទ្ធិ និង និក្ខេប

–ការរក្សាទុកដាក់ទ្រព្យសម្បត្តិដែលមានចែងក្នុង «គណនេយ្យបូជាតុ»

មាត្រា ១៤ : គណនេយ្យករសាធារណៈទទួលភារកិច្ចដឹកនាំប៉ុស្តិ៍គណនេយ្យ ។ ប៉ុស្តិ៍គណនេយ្យត្រូវបាន គ្រប់គ្រងដោយគណនេយ្យករតែមួយ ។ គណនេយ្យករអាចប្រគល់សិទ្ធិ អោយទៅអាជ្ញានុ ការីមួយ ឬ ច្រើនរូបដែលមានលក្ខណៈសម្បត្តិធ្វើការក្នុងនាមខ្លួន និង ក្រោមការទទួលខុស ត្រូវរបស់ខ្លួន ។

មាត្រា ១៥ : គណនេយ្យករសាធារណៈ ត្រូវបានតែងតាំងដោយមានសេចក្តីយល់ព្រមពីរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុជាចាំបាច់ ។ លិខិតតែងតាំងត្រូវបានផ្សព្វផ្សាយ ។ មុននឹងចូលបំ ពេញការងារគណនេយ្យករសាធារណៈ ត្រូវ ធ្វើសច្ចាប្រណិធាន ។ គណនេយ្យករទាំងនេះ តែងតាំងឡើងសំរាប់អមអាណាប័ក ហើយនិងក្នុងករណីខ្លះអមគណនេយ្យករសាធារណៈ ឯទៀតដែលខ្លួនមានការទាក់ទង ។ គណនេយ្យករសាធារណៈត្រូវផ្តល់របាយការណ៍យ៉ាងតិចមួយ ឆ្នាំម្តង ។

មាត្រា ១៦ : ក្នុងល័ក្ខខ័ណ្ឌកំណត់ដោយច្បាប់ជាធរមាន គណនេយ្យករសាធារណៈទទួលខុសត្រូវផ្ទាល់ខ្លួន និងជាប្រាក់កាសពីកិច្ចប្រតិបត្តិការដែលខ្លួនទទួលបន្ទុកតាមន័យក្នុងមាត្រា ១២ និងអនុវត្ត ការត្រួតពិនិត្យដោយទៀងទាត់តាមខ្លឹមសារដូចមានចែងក្នុងមាត្រា ១៣ ។

មាត្រា ១៧ : គណនេយ្យករ និង អាណាប័កមានមុខងារពិសមិតគ្នា ។ ប្តី ឬ ប្រពន្ធរបស់អាណាប័ក ពុំអាចធ្វើជាគណនេយ្យករអោយអង្គការសាធារណៈ ដែលខ្លួនជា អាណាប័កបំពេញមុខងារ នៅទីនោះ ។

មាត្រា ១៨ : ប្រភេទគណនេយ្យករសាធារណៈរបស់រដ្ឋ មានដូចតទៅគឺ ÷

–គណនេយ្យករផ្ទាល់របស់គេនាគារ

–គណនេយ្យករ រដ្ឋបាលហិរញ្ញវត្ថុ

មាត្រា ១៩ : ក្រោមអំណាចនៃរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គណនេយ្យករផ្ទាល់របស់រតនាគារដើមខ្សែ ឬ រង ត្រូវអនុវត្តរាល់កិច្ចប្រតិបត្តិការចំណូល ឬ ចំណាយថវិកាទូទៅ និងគណនេយ្យពិសេស នៃរតនាគារ រាល់កិច្ចប្រតិបត្តិការរតនៈវត្ថុ និងជាទូទៅរាល់កិច្ចប្រតិបត្តិការសន្សំហិរញ្ញវត្ថុដែលរដ្ឋ ទទួលបន្ទុក លើកលែងតែកិច្ចប្រតិបត្តិការណាដែលការអនុវត្តន៍ ត្រូវបានប្រគល់អោយគណនេយ្យករសាធារណៈផ្សេងទៀត ។

មាត្រា ២០ : គណនេយ្យកររតនាគារជាតិ ដែលជាគណនេយ្យករកណ្តាលនៃរតនាគារនៅភ្នំពេញមានលក្ខណៈសម្បត្តិជាគណនេយ្យករដើមខ្សែ ។

គណនេយ្យករនេះ អនុវត្តកិច្ចប្រតិបត្តិការរបស់អាណាប័កដើមខ្សែ និង ប្រមូលផ្តុំនូវរាល់កិច្ចប្រតិបត្តិការ ដែលធ្វើឡើងដោយគណនេយ្យកររតនាខេត្ត–ក្រុង និងគណនេយ្យករនៃអគ្គការរដ្ឋបាលហិរញ្ញវត្ថុ ។ គណនេយ្យករដើមខ្សែនេះអនុវត្ត និង ប្រមូលផ្តុំកិច្ចប្រតិបត្តិការរតនៈវត្ថុរបស់រដ្ឋជាមួយវិទ្យាស្ថានបោះប្រាក់ និក្ខិត្តកររបស់រតនាគារដែលមានលក្ខណៈជាតិ និង ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ។ គណនេយ្យករនេះ បង្កើតឡើងនូវគណនីប្រចាំឆ្នាំរបស់រដ្ឋក្រោយពេលដែលប្រមូលផ្តុំកិច្ចប្រតិបត្តិការថវិកាទូទៅ និង គណនីពិសេស ។

មាត្រា ២១ : គណនេយ្យកររបស់រតនាគារខេត្ត–ក្រុង មានលក្ខណៈសម្បត្តិជាគណនេយ្យកររង អនុវត្តកិច្ច ប្រតិបត្តិការរបស់អាណាប័កតាមការប្រទានសិទ្ធិ នៅតាម មណ្ឌលខេត្ត – ក្រុងរបស់ខ្លួន ។

មាត្រា ២២ : គណនេយ្យកររដ្ឋបាលហិរញ្ញវត្ថុ មានភារកិច្ចប្រមូលពន្ធដារ ពន្ធគយ បំណុលពន្ធផលិត ផលនៃទ្រព្យសម្បត្តិរដ្ឋ និង ចំណូលផ្សេង ។ ព្រមទាំងការពិន័យសារពើពន្ធ និង សោហ៊ុយទារប្រាក់ពន្ធ និង សោហ៊ុយតុលាការដែលពាក់ព័ន្ធក្នុងល័ក្ខខ័ណ្ឌកំណត់ដោយច្បាប់ និង បទបញ្ញា ។ គណនេយ្យករនោះត្រូវបង់ចូលទៅ រតនាគារជាតិនូវ ប្រាក់ចំណូលដែលខ្លួនប្រមូលបានតាមសមយិកភាព កំណត់អោយសាភថរ ។

ជំពូកទី ៣

វិជ្ជាគណនេយ្យករ

មាត្រា ២៣ : វិជ្ជាគណនេយ្យករមួយចំនួនអាចទទួលបន្ទុកជំនួសគណនេយ្យករសាធារណៈ

ក្នុងកិច្ចប្រតិបត្តិការប្រមូលចូលបេឡា និង ចំណាយ ទូទាត់ ។

រជ្ជទេយ្យចំណូល និង រជ្ជទេយ្យបុរេប្រទានរបស់រដ្ឋ ត្រូវបានបង្កើតដោយប្រកាសរួមរបស់ក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង សាមីក្រសួងដែលពាក់ព័ន្ធ ។ គណនេយ្យករសាធារណៈរបស់រដ្ឋ ដែលរជ្ជទេយ្យករធ្វើប្រតិបត្តិការជំនួសហៅថា គណនេយ្យករមុខការរបស់អាណាប័កដែលរជ្ជទេយ្យនោះនៅក្រោមចំណុះ ។

មាត្រា ២៤ : រជ្ជទេយ្យចំណូល និង រជ្ជទេយ្យបុរេប្រទាន ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អាណាប័ក របស់ខ្លួន និង គណនេយ្យករមុខការ ។

រជ្ជទេយ្យករទាំងនេះ ក៏ស្ថិតនៅ ក្រោមការផ្ទៀងផ្ទាត់ របស់អធិការកិច្ចហិរញ្ញវត្ថុទូទៅនិងពីអាជ្ញាធរទាំងឡាយដែលមាននីតិសម្បទាត្រួតពិនិត្យនៅ នឹងកន្លែងចំពោះអាណាប័ក និងគណនេយ្យករ មុខការដែរ ។

មាត្រា ២៥ : រជ្ជទេយ្យករទទួលខុសត្រូវផ្ទាល់ខ្លួន និង ជាប្រាក់កាស នូវការរក្សាការពារមូលនិធិដែលខ្លួនទទួលបាន ឬ មូលនិធិទាំងឡាយណាដែលត្រូវបានបុរេប្រទានពីគណនេយ្យករមុខការរក្សា ទុកដាក់លិខិតយុត្តិកម្ម ព្រមទាំងកាន់កាប់គណនេយ្យប្រតិបត្តិការទៀតផង ។

ភាគ III

កិច្ចប្រតិបត្តិការ

ជំពូកទី ១

កិច្ចប្រតិបត្តិការចំណូល

ផ្នែកទី ១

បទបញ្ញត្តិរួម

មាត្រា ២៦ : ចំណូលរបស់រដ្ឋ រួមមាន ពន្ធអាករ សិទ្ធិ និង ចំណូលប្រហាក់ប្រហែលផ្សេងៗទៀត ផលិតផលនៃទ្រព្យសម្បត្តិរដ្ឋ ផាកពិន័យខណ្ឌភាគជាប្រាក់ផ្សេងៗ និង ផលិតផលផ្សេងៗទៀត ដែលអនុញ្ញាតដោយច្បាប់ និង បទបញ្ញាជាធរមាន ឬក៏ចេញមកពីសេចក្តី សំរេចរបស់តុលាការ ឬពីអនុសញ្ញានានា ។

មាត្រា ២៧ : ការបញ្ចូលជាចំណូល គឺចំនួនទឹកប្រាក់ទាំងអស់នៃផលិតផលនានា ដោយគ្មាន

ធ្វើការកាត់កងរវាងចំណូល និង ចំណាយនានាទេ ។ ក្នុងលក្ខខណ្ឌដែលបាន ចែងសំរាប់ចំណូលនីមួយៗ ចំណូលត្រូវបានជំរះជាមុនសិន មុននឹងត្រូវបាន ប្រមូល ។ គណនេយ្យដែលបានជំរះបញ្ជីហើយ ត្រូវមានចេញដីកាចំណូល ។ កិច្ចការជំរះ គឺកំណត់ចំនួនទឹកប្រាក់នៃបំណុលរបស់អ្នកជាប់អាករ ។

មាត្រា ២៨ : ការទូទាត់អាចធ្វើឡើងដោយបង់ជាសាច់ប្រាក់ ដោយប្រគល់មូលប្បទានប័ត្រ ឬ ផលប័ត្រធនាគារ ឬ បង្វែរចូលគណនីខេប្រាក់ទំនេរណាមួយ ដែលបានបើក ក្នុងនាមគណនេយ្យករ សាធារណៈ ។

ចាប់ពីកំរិតទឹកប្រាក់មួយដែលកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុនោះការទូទាត់ជាចាំបាច់ត្រូវធ្វើតាមមូលប្បទានប័ត្រ ឬ ផលប័ត្រ ធនាគារ ឬ មួយដោយការបង្វែរ ។

មាត្រា ២៩ : ការបង់ជាសាច់ប្រាក់ត្រូវចេញបង្កាន់ដៃជូន ។ ទំរង់នៃបង្កាន់ដៃ និង លក្ខខណ្ឌ នានាសំរាប់ ចេញបង្កាន់ដៃនោះ ត្រូវបានកំណត់ដោយក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ ។

លើកលែងវិធានដែលបានចែងនៅវគ្គទី ១ នៃមាត្រានេះ ពុំត្រូវមានចេញបង្កាន់ ដៃទេ :

-បើកាលណាអ្នកជាប់អាករបង់ប្រាក់ជាតែមប្រ៊ី តំរូបអន្ត និង ជាទូទៅការ ផ្តុកផ្តងសំភារៈ ដែល បានបញ្ជាក់គ្រប់គ្រាន់អំពីការទូទាត់នៃសិទ្ធិនោះ ។

-បើមានការបញ្ជាកទទួលប្រាក់លើឯកសារ ប្រគល់ទៅអ្នកជាប់អាករវិញ ។

មាត្រា ៣០ : បើការប្រមូលដោយសម្រុះសម្រួលពុំអាចធ្វើទៅបាន នោះការប្រមូលគណ នេយ្យដោយបង្ខំត្រូវ បាន ប្រព្រឹត្តទៅអាស្រ័យដោយអំណាចនៃមូលប័ត្រដែល មានឥទ្ធិពលបង្ខំអោយប្រតិបត្តិ ។

មាត្រា ៣១ : វិធានផ្ទាល់និងប្រភេទគណនេយ្យនីមួយៗ ត្រូវកំណត់លក្ខខណ្ឌដែលក្នុងនោះ ការប្រមូលគណនេយ្យអាចត្រូវព្យួរទុក ឬ បោះបង់ចោល ឬ មួយក្នុងលក្ខខណ្ឌ បន្ធូរបន្ថយបំណុល ឬ ការចរចាណាមួយអាចកើតមានឡើង ។

មាត្រា ៣២ : គណាយិករបស់រដ្ឋត្រូវបានរួចខ្លួន បើគណាយិកនោះបង្ហាញបង្កាន់ដៃត្រឹមត្រូវ បើគណាយិកនោះ មានសំអាងលើអាជ្ញាយុកាល ឬ ត្រូវគណនេយ្យករសាធារណៈ ណាមួយទទួលស្គាល់ថា បានបង់ជាផលប័ត្រធនាគារដែលជាគុណប្រយោជន៍

ដល់រតនាគារហើយ ។

ផ្នែកទី ២

ពន្ធដារ និង ចំណូលប្រហាក់ប្រហែល

មាត្រា ៣៣ : ពន្ធដារ និង ចំណូលប្រហាក់ប្រហែលត្រូវបានជំរះឡៀងផ្ទាត់ និង ប្រមូលសមស្របតាមលក្ខខណ្ឌដែលបានចែងដោយច្បាប់ និង បទបញ្ញត្តិដែលពាក់ព័ន្ធ ។

ផ្នែកទី ៣

ផលិតផលនៃទ្រព្យសម្បត្តិរដ្ឋ

មាត្រា ៣៤ : ផលិតផលនៃទ្រព្យសម្បត្តិរដ្ឋ និង ចំណូលប្រហាក់ប្រហែល ត្រូវបានជំរះឡៀងផ្ទាត់ និង ប្រមូលអោយសមស្របតាមលក្ខខណ្ឌដែលច្បាប់ និង បទបញ្ញាបានចែងចំពោះទ្រព្យសម្បត្តិរបស់រដ្ឋ ។

ក្នុងករណីគ្មានអាញត្តិដោយឡែក ហើយក្នុងដំណាក់អន្តរកាលផលិតផលនៃទ្រព្យសម្បត្តិរដ្ឋត្រូវជំរះឡៀងផ្ទាត់ និង ប្រមូលទៅតាមលក្ខខណ្ឌដែលមានចែងក្នុងផ្នែកទី ៥ ដូចខាងក្រោមនេះ ។

ផ្នែកទី ៤

ពិន័យ និង ទណ្ឌទានជាប្រាក់កាសផ្សេងៗ

មាត្រា ៣៥ : ទណ្ឌវាទនឹងពិន័យជាប្រាក់កាស រួមមាន ÷

- ពិន័យជាព្រហ្មទណ្ឌ រដ្ឋប្បវេណី និង រដ្ឋបាល និង ពិន័យជាសារពើពន្ធផ្សេងៗ ទៀត
- ការរិបអូស ជួសជុល សំណងការខូចខាត និង ការប្រាក់យឺតយ៉ាវ
- សោហ៊ុយតុលាការ

ពន្ធតែមប្រើ និង ចុះបញ្ជីកា « គឺទណ្ឌវាទជាប្រាក់កាស »

មាត្រា ៣៦ : ការប្រមូលប្រាក់កាសពីទណ្ឌវាទ ត្រូវបានប្រគល់អោយគណនេយ្យករផ្ទាល់របស់រតនាគារ ។ ការទារប្រមូលនេះ គឺធ្វើទៅលើទណ្ឌិត ឥណាយិករួម បុគ្គលិកស៊ីវិលទទួលខុសត្រូវ និង ប្រតិសិទ្ធិទៅតាមច្បាប់ ។

មាត្រា ៣៧ : លក្ខខណ្ឌពីការបង់ផាកពិន័យបទល្មើសចរាចរ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ផ្នែកទី ៥

បំណុលផ្សេងៗ

មាត្រា ៣៨ : ការជំរះឥណទេយ្យរបស់រដ្ឋ ក្រៅពីឥណទេយ្យដែលមានចែងនៅផ្នែក ២. ៣ និង ៤ ខាងលើ ត្រូវប្រតិបត្តិតាមប្រភេទនៃឥណទេយ្យលើមូលដ្ឋានដែលកំណត់ដោយច្បាប់បទបញ្ញាសេចក្តីសំរេចរបស់តុលាការ ឬ អនុសញ្ញានានា ។

មាត្រា ៣៩ : ឥណទេយ្យណាមួយដែលបានជំរះ ត្រូវភាក់ព័ន្ធទៅនឹងដីកាចំណូលដោយបញ្ជាក់ច្បាស់ពីមូល ដ្ឋាននៃកិច្ចជំរះ ។

ការភ័ន្តច្រឡំនៃកិច្ចជំរះធ្វើអោយខូចប្រយោជន៍ ... ត្រូវតែចេញដីកាអោយលុបចោល ឬ បន្ថយចំណូល ។ បញ្ហានេះ ត្រូវបញ្ជាក់មូល ... នៃកិច្ចជំរះបញ្ជីថ្មីនេះ ។

មាត្រា ៤០ : ដីកាចំណូលត្រូវផ្ញើជូនទៅអ្នកជាប់អាករដោយអាណាប័ក ឬ ដោយគណនេយ្យករ តាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

មាត្រា ៤១ : បើការប្រមូលដោយសម្រុះសម្រួលមិនអាចធ្វើទៅបាន ប្រាក់ចំណូលត្រូវប្រមូលដោយបង្ខំក្នុងលក្ខខ័ណ្ឌដែលបានចែងដោយច្បាប់ និង បទបញ្ញា ។

ផ្នែកទី ៦

រដ្ឋទេយ្យនៃចំណូល

មាត្រា ៤២ : លើកលែងតែបដិប្បញ្ញត្តិដែលយល់ព្រមដោយរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពន្ធ សិទ្ធិ និង អាករ ដែលមានលក្ខណៈជាសារពើពន្ធ មិនអាចប្រមូលតាមរយៈនៃរដ្ឋទេយ្យបានទេ ។

ប្រភេទនៃផលិតផលដែលត្រូវបង់ចូលដោយផ្នែកតាមបទបញ្ញត្តិក្នុងវគ្គមុខ ត្រូវបានកំណត់ដោយ ប្រកាសនានា ដែលមានចែងក្នុងមាត្រា ២៣ ខាងលើ ។

មាត្រា ៤៣ : ក្នុងលក្ខខ័ណ្ឌដូចគ្នានឹងគណនេយ្យសាធារណៈ រដ្ឋទេយ្យករប្រមូលចំណូលពីអ្នក ជាប់អាករអាចយកជាសាច់ប្រាក់ ឬ ដោយមូលប្បទានប័ត្រធនាគារ ឬ ដោយបង្វែរគណនីទៅធនាគារ ។

មាត្រា ៤៤ : រដ្ឋទេយ្យករបង់ចំណូលដែលប្រមូលបានអោយគណនេយ្យករមុខការ ។
ការបង់ចំណូលនេះ ត្រូវធ្វើឡើងជាអប្បបរមាមួយខែម្តង ។ មូលប្បទានប័ត្រធនាគារ ត្រូវប្រគល់ជូនគណនេយ្យករ មុខការយ៉ាងយូរបំផុតមួយថ្ងៃក្រោយ

ដែលបានទទួល ។

ជំពូកទី ២

កិច្ចប្រតិបត្តិការចំណាយ

មាត្រា ៤៥ : ចំណាយទាំងឡាយរបស់រដ្ឋ ត្រូវតែគ្រោងនៅក្នុងថវិកា ហើយត្រូវអោយស្រប តាមច្បាប់ និង បទបញ្ជា ។

មាត្រា ៤៦ : មុននឹងធ្វើការទូទាត់ ចំណាយ ត្រូវតែបានធ្វើកិច្ចសន្យាជំរះនិង ធ្វើអាណាប័ណ្ណ ។

ផ្នែកទី ១

កិច្ចសន្យា

មាត្រា ៤៧ : កិច្ចសន្យាជាប្រព្រឹត្តិកម្មមួយដែលរដ្ឋបង្កើត ឬ ជាកំណត់សំគាល់មួយថា ខ្លួនត្រូវមានកាតព្វកិច្ច ទទួលបន្ទុកក្នុងកិច្ចការនេះ ។

មាត្រា ៤៨ : មានតែអាណាប័កទេ ដែលមានឋានៈអាចធ្វើសន្យាចំណាយរបស់រដ្ឋបាន ។

មាត្រា ៤៩ : ផ្អែកតាមបទបញ្ញត្តិពិសេសចំពោះឥណទានដែលអាចវាយតម្លៃបាន កិច្ចសន្យា ត្រូវបានកំណត់ក្នុង ទឹកប្រាក់ឥណទាន ដែលបានអនុញ្ញាតយ៉ាងត្រឹមត្រូវដោយ ច្បាប់ហិរញ្ញវត្ថុ ។

សង្វាក់នៃកិច្ចសន្យាប្រចាំខែទាំងឡាយ ត្រូវកំណត់ឡើងដោយរដ្ឋមន្ត្រី ក្រសួង សេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ ទៅតាមការប្រមូលបាននៃចំណូល ។

មាត្រា ៥០ : កិច្ចសន្យាត្រូវបានចុះបញ្ជីការគណនេយ្យកាន់ដោយអាណាប័កដើមខ្សែ និង ដោះ អាណាប័កតាម ការប្រទានសិទ្ធិក្នុងករណីមួយដែលបានប្រគល់សិទ្ធិអោយ ។

ផ្នែកទី ២

កិច្ចជំរះបញ្ជី

មាត្រា ៥១ : កិច្ចជំរះបញ្ជីមានវត្ថុបំណងផ្ទៀងផ្ទាត់ភាពពិតប្រាកដនៃបំណុល និង បញ្ជាក់ ទឹកប្រាក់ចំណាយ ។ កិច្ចជំរះបញ្ជីនេះធ្វើឡើងក្រោយពីបានឃើញមូលប័ត្រ បញ្ជាក់ពីសិទ្ធិរបស់ឥណទាយក ។

មាត្រា ៥២ : ចំណាយរបស់រដ្ឋ ត្រូវជំរះដោយអាណាប័ក ។

ជំពូកទី ៣

អាណាប័ណ្ណ

មាត្រា ៥៣ : អាណាប័ណ្ណជាប្រព្រឹត្តិកម្មរដ្ឋបាល ដែលបញ្ជាអោយរដ្ឋសងបំណុលរបស់រដ្ឋ ដោយស្របតាម លទ្ធផលនៃកិច្ចជំរះ ។

មាត្រា ៥៤ : ចំណាយទាំងឡាយរបស់រដ្ឋ ត្រូវធ្វើអាណាប័ណ្ណដោយអាណាប័ក ។ ដើម្បីសំរេចកិច្ចនេះ អាណាប័កចេញអាណត្តិបើកប្រាក់ ។

អាណត្តិចេញដោយអាណាប័កដើមខ្សែ ត្រូវចុះបំពេញតាមប្រភេទនៃឥណទាន ដែលបានផ្តល់ជូនដោយថវិកា ។ អាណត្តិចេញដោយអាណាប័កតាមការប្រទានសិទ្ធិត្រូវចុះបំពេញតាមប្រភេទ នៃឥណទានដែលប្រគល់ដោយ អាណាប័កដើមខ្សែតាមរយៈប្រកាសសិទ្ធិប្រទាន ។

មាត្រា ៥៥ : អាណត្តិ និង ប្រកាសសិទ្ធិប្រទានឥណទាន ត្រូវឆ្លងទិដ្ឋាការជាមុនពីអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ។

អាណត្តិ និង ប្រកាសសិទ្ធិប្រទានឥណទានណាដែលគ្មានទិដ្ឋាការរបស់អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ គឺពុំមានតម្លៃទេចំពោះគណនេយ្យករ ។

មាត្រា ៥៦ : អាណត្តិដែលចេញដោយរដ្ឋមន្ត្រីក្នុងនាមអាណាប័កដើមខ្សែ និង ចេញដោយអ្នកទទួលខុសត្រូវនៃរដ្ឋបាលកណ្តាល ក្នុងនាមអាណាប័កតាមការប្រទានសិទ្ធិ ត្រូវបានទាត់តាំងដោយ គណនេយ្យករកណ្តាលរបស់រតនាគារ ។

អាណត្តិចេញដោយអភិបាលខេត្ត-ក្រុង ក្នុងនាមអាណាប័កតាមការប្រទានសិទ្ធិ ត្រូវបានទាត់ តែងដោយគណនេយ្យកររងរបស់រតនាគារខេត្ត-ក្រុង ដែលជានិវេសដ្ឋានរបស់អភិបាលខេត្ត-ក្រុងនោះ ។

ជំពូកទី ៤

ការទូទាត់

មាត្រា ៥៧ : ការទូទាត់គឺជាប្រព្រឹត្តិកម្ម ដែលរដ្ឋត្រូវបានរំដោះបំណុលរបស់ខ្លួន ។

លើកលែងករណីដែលបានចែងដោយច្បាប់ និង បទបញ្ញា ការទូទាត់ពុំអាចធ្វើទៅបានមុនរយៈ ពេលត្រូវសងបំណុល ឬ មុនការអនុវត្តនៃសេវាបានឡើយ ។

ប៉ុន្តែពេលខ្លះប្រាក់រំដោះ ឬ ប្រាក់បុរេប្រទាន អាចប្រគល់អោយសហគ្រិន ឬ អ្នកផ្គត់ផ្គង់បានក្នុងល័ក្ខខ័ណ្ឌចែងដោយបទបញ្ញាជាធរមាន ។

មាត្រា ៥៨ : គណនេយ្យករមុខការដែលចែងនៅក្នុងមាត្រា ៥៦ខាងលើចាត់វិធីទូទាត់អាណត្តិ ។
កិច្ចការទូទាត់អាចធ្វើឡើងដោយការប្រគល់សាច់ប្រាក់ មូលប្បទានប័ត្រ ឬ ដោយផ្ទេរ ។

មាត្រា ៥៩ : នៅឱកាសអនុវត្តការត្រួតពិនិត្យទៅតាមមាត្រា ១៣ ខាងលើ បើកត់សំគាល់ឃើញមានភាពមិន ត្រឹមត្រូវ នោះគណនេយ្យករសាធារណៈត្រូវព្យួរទុកការទូទាត់ ហើយត្រូវផ្តល់ពត៌មានដល់អាណាប័ក ។
ការទូទាត់ក៏អាចព្យួរទុកបានដែរ កាលណាគណនេយ្យករសាធារណៈបានពិនិត្យឃើញសេចក្តី បញ្ជាក់ដែលមានកំណត់ក្នុងមាត្រា ១០ ពុំមានភាពត្រឹមត្រូវ ។

មាត្រា ៦០ : ដោយអនុវត្តវគ្គចុងក្រោយនៃមាត្រា ៨ ខាងលើ នៅពេលដែលអាណាប័កទាមទារបង្ខំអោយ គណនេយ្យករធ្វើការទូទាត់នោះ គណនេយ្យករព្រមអនុវត្តតាមបញ្ជា រួចហើយត្រូវរាយការណ៍ជូនរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។
បញ្ជា ទាមទារបង្ខំចេញដោយអាណាប័ក ត្រូវបានបញ្ជូនទៅតុលាការគណនីដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មាត្រា ៦១ : ដោយបដិប្បញ្ញត្តិទៅនឹងបទបញ្ញត្តិនៃវគ្គទីមួយ នៃមាត្រាខាងលើនេះ គណនេយ្យករត្រូវបដិសេធ បញ្ជាទាមទារបង្ខំទាំងនោះ កាលណាការព្យួរទុកនៃការទូទាត់មានមូលហេតុបណ្តាលមកពី ÷
- ភាពមិនទំនេរ នៃឥណទាន
- ពុំមានទិដ្ឋាការលើអាណត្តិ ដោយអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ
- ពុំមានយុត្តិកម្ម (ការបញ្ជាក់) ពីសេវាដែលបានធ្វើហើយ (Service fait)
- លក្ខណៈមិនអោយរួចបំណុល នៃការទូទាត់

ក្នុងករណីបដិសេធបញ្ជាទាមទារបង្ខំ គណនេយ្យករត្រូវរាយការណ៍ភ្លាមជូនរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធ្វើការសំរបសំរួលជាមួយរដ្ឋមន្ត្រីដែលពាក់ព័ន្ធ ។

មាត្រា ៦២ : រាល់ការកែតាស់ ឬ ការអះអាងទិណភាពផ្សេងៗដែលមានកម្មវត្ថុបញ្ឈប់ការទូទាត់ ត្រូវធ្វើឡើងដោយ ផ្ទាល់ដៃនៃគណនេយ្យករសាធារណៈមុខការចំណាយ ។

មាត្រា ៦៣ : សំណុំទាំងឡាយដែលក្នុងនោះគណនេយ្យមិនបានទូទាត់ ត្រូវបានផុតរលត់ជាស្ថាពរ ហើយជាប្រយោជន៍រដ្ឋត្រូវកំណត់ដោយច្បាប់ ។

ផ្នែកទី ៥

កិច្ចដំណើរការ រដ្ឋទេយ្យប្បទាន

មាត្រា ៦៤ : លើកលែងតែបដិប្បញ្ញត្តិដែលយល់ព្រមដោយរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបានទូទាត់តាមរយៈរដ្ឋទេយ្យនូវ ÷

១– ចំណាយកំប៉ុកកំប៉ុកអំពីសំភារៈក្នុងចំនួនទឹកប្រាក់ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

២– លាភការទាំងឡាយរបស់បុគ្គលិក

៣– សង្គ្រោះជាបន្ទាន់ និង ពិសេស

៤– ចំណាយធ្វើដំណើរ និង ប្រាក់បំណាច់បេសកកម្ម

មាត្រា ៦៥ : ត្រូវទុកលទ្ធភាពសំរាប់អោយរដ្ឋទេយ្យករនីមួយៗ នូវបុរេប្រទានមួយដែលមានទឹកប្រាក់កំណត់ ដោយអាណត្តិដែលបានបង្កើតចេញរដ្ឋទេយ្យ និង ដាយថាហេតុអាណត្តិនេះត្រូវបានលើបើឡើង វិញក្រោមរូបភាពដូចគ្នា ។

លើកលែងតែបដិប្បញ្ញត្តិយល់ព្រមដោយរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំនួនប្រាក់បុរេ ប្រទាននេះជាអតិបរិមាស្មើនឹងមួយភាគប្រាំបី នៃចំនួនទឹកប្រាក់គ្រោងចំណាយប្រចាំឆ្នាំ ដែល រដ្ឋទេយ្យករអាចទូទាត់បាន ។

បុរេប្រទាន ត្រូវបង់ដោយគណនេយ្យករសាធារណៈមុខការ ផ្អែកតាមសំណើរបស់រដ្ឋទេយ្យករ ដែលមានចុះទិដ្ឋាការដោយអាណាប័ក ។

មាត្រា ៦៦ : ក្នុងល័ក្ខខ័ណ្ឌដូចគ្នានឹងគណនេយ្យសាធារណៈ រដ្ឋទេយ្យករ ធ្វើប្រតិបត្តិការទូទាត់ចំណាយដោយបង្កៀរ ឬ ដោយមូលប្បទានប័ត្រ លើគណនីរបស់ខ្លួននៅរតនាគារ ឬ មួយដោយសាច់ប្រាក់ក៏បាន ។

មាត្រា ៦៧ : រដ្ឋទេយ្យករប្រគល់លិខិតយុត្តិការចំណាយដែលបានទូទាត់ដោយខ្លួនផ្ទាល់ជូនអាណាប័កយ៉ាងយូរ បំផុតក្នុងរយៈពេលមួយខែ ចាប់ពីកាលបរិច្ឆេទទូទាត់ចំណាយ ។

ចំពោះទឹកប្រាក់ចំណាយណា ដែលទទួលស្គាល់ថាត្រឹមត្រូវហើយនោះអាណាប័កចេញអាណត្តិ និយ័តកម្មមួយ ដើម្បីជាគុណប្រយោជន៍ដល់រដ្ឋទេយ្យករ ។

ប្រាក់បុរេប្រទាន ត្រូវបានប្រមូលមកវិញដោយកត់ត្រាទឹកប្រាក់អាណត្តិនិយ័តកម្មនេះ ចុះខាងឥណទាននៃគណនីប្រាក់បញ្ញើរបស់រដ្ឋទេយ្យករ ក្នុងលេខនារបស់គណនេយ្យករមុខការ ។

ជំពូកទី ៣

ប្រតិបត្តិការរតនៈវត្ថុ

ផ្នែកទី ១

គោលការណ៍ទូទៅ

មាត្រា ៦៨ : ដែលហៅថាប្រតិបត្តិការរតនៈវត្ថុ គឺរាល់ចលនាសាច់ប្រាក់ តម្លៃដែលអាចគេណនាប្រមូលបានគណនីនិក្ខិត្តភ័ណ្ឌ និង គណនីចរន្តហើយនិងប្រតិបត្តិការទាំងឡាយដែលពាក់ព័ន្ធនឹងគណនីឥណទេយ្យ និងបំណុលរយៈពេលខ្លី ។

មាត្រា ៦៩ : ប្រតិបត្តិការរតនៈវត្ថុ ត្រូវបានពណ៌នាតាមប្រភេទទាំងស្រុង ដោយគ្មានការបំព្រួញឡើយ ។ បន្ទុក និង ផលិតផលដែលបណ្តាលមកពីការអនុវត្តន៍កិច្ចបតិបត្តិការរតនៈវត្ថុត្រូវបានកំណត់ក្នុងគណនីថវិកា ។

មាត្រា ៧០ : ប៉ុស្តិ៍គណនេយ្យមួយមានបេឡាតែមួយគត់ ។

មាត្រា ៧១ : អង្គការសាធារណៈ ត្រូវដាក់ផ្ញើទុកមូលនិធិរបស់ខ្លួននៅរតនាគារ វៀរលែងតែមានការអនុញ្ញាត ពីរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មាត្រា ៧២ : មានតែគណនេយ្យករសាធារណៈទេ ដែលមានសម្បទាអោយរក្សាមូលនិធិរបស់រតនាគារ ។

មាត្រា ៧៣ : អាណាប័ក និង ភ្នាក់ងាររដ្ឋផ្សេងៗ ដែលគ្មានលក្ខណៈសម្បត្តិជាគណនេយ្យករសាធារណៈ មិនអាចបើកគណនីក្នុងធនាគារ ឬ គ្រឹះស្ថានឥណទានសាធារណៈ ឬ ឯកជនឡើយ ។

ក៏ប៉ុន្តែ អ្នកទទួលខុសត្រូវអង្គភាពគ្រប់គ្រងគំរោងដែលហិរញ្ញប្បទានដោយជំនួយក្រៅប្រទេស អាចបើកគណនីនៅធនាគារបានសំរាប់តំរូវការរបស់គំរោងក្នុងករណីណាដែលកិច្ចព្រមព្រៀង បានចុះហត្ថលេខាជាមួយអ្នកផ្តល់មូលនិធិ ។ ការបើកគណនីទាំងនេះ ត្រូវឆ្លងកាត់ការអនុញ្ញាត ជាមុនពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ជំពូកទី ២

ប្រាក់សំនៅ និង ចលនានៃមូលនិធិ

មាត្រា ៧៤ : ប្រាក់ទំនេររបស់គណនេយ្យករសាធារណៈនៃរតនាគារ ត្រូវរក្សាទុកក្រោមរូបភាពជា ÷

- សាច់ប្រាក់ក្នុងបេឡា
- និក្ខេបភណ្ឌក្នុងគណនីចរន្តតែមួយ ដែលបើកនៅធនាគារជាតិនៃកម្ពុជា ។

មាត្រា ៧៥ : ប្រាក់ទំនេររបស់គណនេយ្យករនៃរដ្ឋបាលហិរញ្ញវត្ថុ (អគ្គនាយក-គយ) របស់រដ្ឋទេយ្យចំណូល និង រដ្ឋទេយ្យបុរេប្រទាន ត្រូវបានរក្សាទុកក្រោមរូបភាពជា ÷

- សាច់ប្រាក់ក្នុងបេឡា
- និក្ខេបភណ្ឌក្នុងគណនី ដែលបើកក្នុងសៀវភៅនៃគណនេយ្យករផ្ទាល់របស់រតនាគារ ។

មាត្រា ៧៦ : រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កំណត់វិធានទាំងឡាយដែលទាក់ទងដល់ការកំណត់ចំនួន សាច់ប្រាក់ដែលគណនេយ្យករ និង រដ្ឋទេយ្យករត្រូវរក្សាទុក ។

មាត្រា ៧៧ : គណនេយ្យករសាធារណៈរបស់រដ្ឋ មិនអាចបើកគណនីនៅធនាគារ ឬ គ្រឹះស្ថានឥណទាន ដែលមានលក្ខណៈឯកជនបានទេ វៀរលែងតែមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ ។

មាត្រា ៧៨ : ធនាគារជាតិនៃកម្ពុជា ជាអ្នកទទួលរក្សាទុកជាចាំបាច់នូវមូលនិធិទាំងឡាយ ដែលកាន់កាប់ដោយ គណនេយ្យករផ្ទាល់របស់រតនាគារ ។

មាត្រា ៧៩ : បុរេប្រទានដែលធនាគារជាតិនៃកម្ពុជាអាចផ្តល់ជូនរតនាគារ ក្នុងកំរិត និង លក្ខខណ្ឌ ដែលបានកំណត់ដោយច្បាប់ស្តីពីលក្ខន្តិកៈធនាគារ និង ដោយច្បាប់ហិរញ្ញវត្ថុ ត្រូវបានកត់ត្រាក្នុងគណនីតែមួយគត់ដែលបើកនៅក្នុងលេខនារបស់គណនេយ្យករកណ្តាលនៃរតនាគារ ។

មាត្រា ៨០ : ក្រៅពីចលនាសាច់ប្រាក់ដែលទាក់ទងនឹងបុគ្គលទី៣ ឬ ការបង់ប្រាក់ពីបេឡារបស់គណនេយ្យករ រាល់ការទូទាត់រវាងគណនេយ្យករសាធារណៈ ត្រូវធ្វើដោយការផ្ទេរគណនី ។

ផ្នែកទី ៣
និក្ខិត្តករ

មាត្រា ៨១ : ដោយអនុលោមតាមច្បាប់ និង បទបញ្ញាទាំងឡាយ ឬ ដោយអំណាចនៃអនុសញ្ញា និក្ខិត្តកររបស់ធនាគារជាអង្គការ និង ឯកជននានា ដែលផ្ញើទុកមូលនិធិទៅធនាគារក្នុងនាមជាកាតព្វកិច្ច ឬ ដោយឥតបង្ខំ ឬ ដែលត្រូវបានអនុញ្ញាតអោយធ្វើប្រតិបត្តិការចំណូល និង ចំណាយ តាមរយៈ គណនេយ្យកររបស់ធនាគារ ។ វៀរលែងតែមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ និក្ខិត្តករម្នាក់អាចបើកគណនីតែមួយគត់នៅធនាគារ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កំណត់លក្ខខ័ណ្ឌនៃការបើក និង ការប្រព្រឹត្តិទៅនៃគណនី ទាំងឡាយ ដែលបានបើកក្នុងនាមនិក្ខិត្តករ ព្រមទាំងអត្រា និង របៀបបទដំរះបញ្ជីនូវការដែលអាចផ្តល់អោយនិក្ខិត្តករទាំងនោះ ។

មាត្រា ៨២ : គណនេយ្យកររដ្ឋអាចធ្វើប្រតិបត្តិការចំណូល និង ចំណាយទាំងឡាយជាប្រយោជន៍ដល់និក្ខិត្តករ នៃធនាគារក្នុងលក្ខខ័ណ្ឌដែលកំណត់ដោយ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មាត្រា ៨៣ : រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចផ្តល់និតិសម្បទា ដល់គណនេយ្យករនៃធនាគារអោយ កាន់កាប់ផ្នែកទទួលទុកមូលនិធិឯកជន ។

មាត្រា ៨៤ : គណនីដែលបើកនៅធនាគារក្នុងនាមនិក្ខិត្តករ មិនត្រូវមានវិបារូន៍ (ដក ឬ ចាយលុយលើស ចំនួនដែលមានទេ) ។

ជំពូកទី ៤
ការខ្ចី និង សន្សំ

មាត្រា ៨៥ : ប្រាក់បំណុលរបស់ធនាគារមួយអាចកើតមានក្រោមរូបភាពបោះផ្សាយ មូលប័ត្ររយៈពេលវែង រយៈពេលមធ្យម និង រយៈពេលខ្លី ជាឥណទាននៃអ្នកផ្តល់ប្រាក់ ឬ ជាការសន្សំផ្សេងៗទៀតដែលអាច សងតាមដំណាក់កាល ឬ សងតាមឆ្នាំដោយគ្មានការអនុញ្ញាតពីច្បាប់ហិរញ្ញវត្ថុឡើយ ។

ច្បាប់មួយនឹងកំណត់អំពីលក្ខខ័ណ្ឌនៃប្រតិបត្តិការនេះ ។

ជំពូកទី ៥

កិច្ចប្រតិបត្តិការផ្សេងៗ

មាត្រា ៨៦ : ប្រតិបត្តិការទាំងឡាយដែលមិនបានកំណត់ក្នុងជំពូកទី ១ ដល់ ៤ ខាងលើគឺជាប្រតិបត្តិការពាក់ព័ន្ធនឹងទ្រព្យសម្បត្តិរដ្ឋ តម្លៃដែលត្រូវចេះផ្សាយព្រមទាំងវត្ថុ និងតម្លៃដែលជារបស់តតិយជន។

របៀបបទនៃការទទួលបន្ទុកនៃការប្រើប្រាស់ និង នៃការរក្សាទុកទ្រព្យសម្បត្តិ វត្ថុ និង តម្លៃត្រូវ បានកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ជំពូកទី ៦

យុត្តិកម្មនៃកិច្ចប្រតិបត្តិការ

មាត្រា ៨៧ : ប្រតិបត្តិដែលបានចែងក្នុងជំពូកមុនៗ ត្រូវមានលិខិតយុត្តិការជាសំអាង ។

មាត្រា ៨៨ : លិខិតយុត្តិការនៃប្រតិបត្តិការទាំងឡាយត្រូវបានបង្ហាញដល់អង្គការត្រួតពិនិត្យរបស់ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមការស្នើរបស់អង្គការនោះ ។

លិខិតយុត្តិការមិនអាចត្រូវកំទេច ពេលមុនការវិនិច្ឆ័យគណនី ឬ មុនការបញ្ចប់រយៈពេលអាជ្ញាយុកាលនៃការអនុវត្តន៍កិច្ចប្រតិបត្តិទេ ។

មាត្រា ៨៩ : យុត្តិកម្មនៃចំណូលដែលទាក់ទងដល់ថវិកាទូទៅ និង គណនីពិសេសត្រូវបង្កើតឡើងដោយ :

- សេចក្តីចម្លងបញ្ជាក់របស់ដីកាចំណូល
- តារាងផលដែលប្រមូលបាន និង ឥណទេយ្យដែលមិនទាន់ប្រមូលបាន ។
- សំរង់សាលក្រមនៃការវិនិច្ឆ័យ និង កំណត់ហេតុ ។

មាត្រា ៩០ : យុត្តិកម្មនៃចំណាយដែលទាក់ទងដល់ថវិកាទូទៅ និង គណនីពិសេសត្រូវបង្កើតឡើងដោយ :

- អាណត្តិបើកប្រាក់ លិខិតបញ្ជាក់ការពិតនៃសេវាដែលធ្វើហើយ និង សិទ្ធិរបស់ឥណទាយក និងជាយថាហេតុបញ្ជាទានការបង្គំរបស់អាណាប័ក ។
- ឯកសារដែលបញ្ជាក់អំពីលក្ខណៈរបស់ឥណទាយក និង សិទ្ធិអោយទូទាត់បំណុល ព្រមទាំងលិខិតទទួលប្រាក់របស់ឥណទាយក ឬ និទ្ទេសបញ្ជាក់ការសងប្រាក់ ។

មាត្រា ៩១ : យុត្តិកម្មប្រតិបត្តិការរតនៈវត្ថុត្រូវបង្កើតឡើងដោយ
- តារាងអធិប្បាយអំពីសមតុល្យ
- មូលប្បទានប័ត្រ បញ្ជាចំណាយ ឬ បង្កាន់ដៃដែលម្ចាស់គណនីនិក្ខិតភ័ណ្ឌប្រគល់អោយ ។

មាត្រា ៩២ : យុត្តិកម្មដែលមានចែងក្នុងមាត្រាទាំងឡាយខាងលើ ជាកម្មវត្ថុនៃមាតិកាទូទៅមួយ ដែលរៀបចំឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ល្អិតណាប្រតិបត្តិការនេះមិនបានគ្រោងទុកក្នុងមាតិកា ទោះជាយ៉ាងណាក៏ដោយ យុត្តិកម្មដែល អង្គភាពត្រូវពិនិត្យកត់ត្រានូវភាពត្រឹមត្រូវនៃបំណុល និង ការទូទាត់ ។

មាត្រា ៩៣ : ក្នុងករណីមានការបាត់បង់ បំផ្លាញ ឬ លួចលិខិតយុត្តិការដែលបានប្រគល់រួចហើយអោយគណនេយ្យករ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចអនុញ្ញាតអោយគណនេយ្យករនោះ ផ្តល់យុត្តិកម្មជំនួស ។

ជំពូកទី IV

គណនេយ្យ

មាត្រា ៩៤ : គណនេយ្យរដ្ឋមានកម្មវត្ថុធ្វើការពិពណ៌នា និង ត្រួតពិនិត្យនូវប្រតិបត្តិការទាំងឡាយ ព្រមទាំងផ្តល់ពត៌មានរបស់អាជ្ញាធរត្រួតពិនិត្យ និង គ្រប់គ្រង ។
ដើម្បីសំរេចបញ្ហានេះ គណនេយ្យត្រូវរៀបចំឡើងដើម្បីមាន :
- យល់ដឹង និង ត្រួតពិនិត្យ ប្រតិបត្តិការថវិកា និង ប្រតិបត្តិការរតនៈវត្ថុ
- កំណត់លទ្ធផលប្រចាំឆ្នាំ
- បញ្ចូលកិច្ចប្រតិបត្តិការ ក្នុងគណនេយ្យសេដ្ឋកិច្ចជាតិ
- បង្កើតស្ថិតិហិរញ្ញវត្ថុ ដែលបង្ហាញស្របតាមបទដ្ឋាន « ច្បាប់ » អន្តរជាតិ ។

មាត្រា ៩៥ : ក្រោមលក្ខខណ្ឌនៃបទបញ្ញត្តិដែលមានចែងក្នុងមាត្រាទាំងឡាយខាងក្រោម ការកំណត់វិធានទូទៅ នៃគណនេយ្យជាបន្ទុករបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មាត្រា ៩៦ : គណនេយ្យរដ្ឋមាន :
- គណនេយ្យទូទៅ
- គណនេយ្យបំព្រួញ នៃរដ្ឋទេយ្យចំណូល និង បុរេប្រទាន

- គណនេយ្យពិសេស នៃរូបធាតុ តម្លៃ និង មូលប័ត្រ រូបិយវត្ថុបរទេស ព្រមទាំងគំរូលិខិតបំណុល តែមប្រៃ និង លតាប័ត្រទុកសំរាប់បោះផ្សាយ និង លក់ ។

ម្យ៉ាងទៀត គេអាចរៀបចំគណនេយ្យវិភាគមួយ ឬ ច្រើនក្នុងផ្នែកខ្លះ ដោយប្រកាសរួមរបស់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ ។

មាត្រា ៩៧ : គណនេយ្យរដ្ឋ ត្រូវកាន់រូបិយវត្ថុជាតិ

ប្រតិបត្តិការប្តូរប្រាក់ដែលជាប្រតិបត្តិការថវិកា ឬ រតនៈវត្ថុ ដោយរូបិយវត្ថុបរទេសជាសមត្ថកិច្ចផ្តាច់មុខរបស់ធនាគារជាតិកម្ពុជា ។ បដិភាគជាប្រាក់រៀលនៃប្រតិបត្តិការទាំងនោះ ត្រូវបានកត់ត្រាខាងឥណទាន ឬ ខាងឥណពន្ធដោយធនាគារចូលគណនីចរន្តរបស់រតនាគារ ។ រូបិយវត្ថុបរទេសដែលរដ្ឋបាលសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ចំណូលបានពីការបង់ពន្ធ សិទ្ធិអាករ និងផលិតផលផ្សេងៗ ត្រូវបានប្រគល់អោយគណនេយ្យកររតនាគារដើម្បីបង់ចូលធនាគារជាតិនៃកម្ពុជា ហើយប្តូរជាប្រាក់រៀលមុននឹងកត់ត្រាចូលគណនីចំណូលថវិកាទាំងឡាយដែលត្រូវគ្នា ។

ជំពូកទី ១

គណនេយ្យទូទៅ

មាត្រា ៩៨ : គណនេយ្យទូទៅរបស់រដ្ឋបង្ហាញ

- ប្រតិបត្តិការ ថវិកា
- ប្រតិបត្តិការ រតនៈវត្ថុ
- ប្រតិបត្តិការ ធ្វើជាមួយតតិយជន

គណនេយ្យទូទៅ បញ្ចេញអោយឃើញនូវលទ្ធផលនាជំណាច់ឆ្នាំ ។

គណនេយ្យទូទៅ ត្រូវបានកាន់តាមវិធីទ្វេភាគ ។

មាត្រា ៩៩ : គណនេយ្យទូទៅរបស់រដ្ឋ ត្រូវបានកាន់អនុលោមតាមប្លង់គណនេយ្យមួយដែលកំណត់ដោយរដ្ឋ មន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មាតិកាគណនី ដែលបើកក្នុងគណនេយ្យទូទៅកំណត់បែបបទនៃការប្រព្រឹត្តទៅនៃគណនីទាំង ឡាយ ។

មាតិកាទាំងនេះត្រូវ រៀបចំឡើងតាមលំនាំប្លង់គណនេយ្យទូទៅ ។

មាត្រា ១០០ : ក្នុងល័ក្ខខ័ណ្ឌ និង ព្រំដែននៃមុខការរបស់គណនេយ្យករនីមួយៗ គណនេយ្យទូទៅរបស់រដ្ឋត្រូវ បានកាន់ដោយគណនេយ្យករផ្ទាល់របស់រតនាគារ និង ដោយគណនេយ្យករ នៃរដ្ឋបាល ហិរញ្ញវត្ថុ ។

គណនេយ្យនេះ ត្រូវបានប្រមូលផ្តុំដោយគណនេយ្យករកណ្តាលនៃរតនាគារ ។

គណនេយ្យនេះ ត្រូវបានផ្សព្វផ្សាយរាល់ខែ ក្នុងល័ក្ខខ័ណ្ឌដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ជំពូកទី ២

គណនេយ្យរដ្ឋនេយ្យ

មាត្រា ១០១ : រដ្ឋនេយ្យករ មានភារកិច្ចកាន់គណនេយ្យដែលទម្រង់គណនេយ្យនេះត្រូវបានកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬ ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

គណនេយ្យនេះ ត្រូវបង្ហាញអោយឃើញគ្រប់ពេលនូវ :

ស្ថានភាពប្រាក់ក្នុងបេឡា ចំពោះរដ្ឋនេយ្យចំណូល

- ស្ថានភាពបុរេប្រទានបានទទួល ចំពោះរដ្ឋនេយ្យបុរេប្រទាន ។

ជំពូកទី ៣

គណនេយ្យពិសេស

មាត្រា ១០២ : គណនេយ្យពិសេសនៃរូបធាតុ តម្លៃ និង មូលប័ត្រ មានកម្មវត្ថុពិពណ៌នាចំនួនដែលមានស្រាប់ និង ចលនាដែលទាក់ទងនឹង :

- សំភារៈ និង ទ្រព្យសង្ហារឹម
- មូលប័ត្រមានចុះឈ្មោះ គ្មានឈ្មោះ និង តាមបញ្ជា រូបិយវត្ថុបរទេស និង តម្លៃផ្សេងៗរបស់ រដ្ឋ ឬ ដែលត្រូវប្រគល់ផ្ញើទុកនឹងរដ្ឋ ។
- រូបិយវត្ថុបរទេស ក្នុងករណីដែលបានចែងក្នុងវគ្គទីបី នៃមាត្រា ៩៧ ខាងលើ
- តំរូលិខិត , មូលប័ត្រ , ប័ណ្ណ , តែមប្រិ៍ និង លតាប័ត្រទុកសំរាប់បោះផ្សាយ និង លក់ ។

វិធានគណនេយ្យ ត្រូវបានកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មាត្រា ១០៣ : គណនេយ្យពិសេស ត្រូវបានកាន់ដោយគណនេយ្យករជួ ឬ ដោយរដ្ឋទេយ្យករ ឬ អ្នកកាន់កាប់ដោយឡែក ។

មាត្រា ១០៤ : គណនេយ្យកររដ្ឋទទួលបន្ទុកកាន់គណនេយ្យពិសេស ត្រូវភ្ជាប់ជាមួយនឹងគណនីគ្រប់គ្រងប្រចាំឆ្នាំរបស់ខ្លួននូវគណនីគ្រប់គ្រង « រូបធាតុ , តម្លៃ , និងមូលប័ត្រ » ដែលរៀបចំក្នុងល័ក្ខខ័ណ្ឌ កំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ជំពូកទី ៤

ភាពប្រចាំឆ្នាំ ការបោះតែងគណនេយ្យ

មាត្រា ១០៥ : គណនេយ្យ ត្រូវបានកាន់តាមឆ្នាំ ។ គណនេយ្យនៃឆ្នាំនីមួយៗមាន :

- ប្រតិបត្តិការថវិកាទាំងអស់ដែលពាក់ព័ន្ធ ជាមួយថវិកានៃឆ្នាំដែលអនុវត្ត ។
- ប្រតិបត្តិការរតនៈវត្ថុទាំងអស់ និង ប្រតិបត្តិការដែលមានចែងក្នុងមាត្រា ៨៦ ខាងលើ ដែលបាន ធ្វើក្នុងអំឡុងឆ្នាំ ព្រមទាំងប្រតិបត្តិការនិយ័តកម្ម ។

មាត្រា ១០៦ : ចំណូលត្រូវបានគិតចូលក្នុងថវិកានៃឆ្នាំ ដែលក្នុងអំឡុងនោះ ចំណូលទាំងនេះត្រូវបានប្រមូល ដោយគណនេយ្យសាធារណៈ ។

មាត្រា ១០៧ : ចំណាយត្រូវបានគិតចូលក្នុងថវិកានៃឆ្នាំ ដែលក្នុងអំឡុងនោះ អាណត្តិនៃចំណាយត្រូវបានចុះទិដ្ឋាការដោយគណនេយ្យករមុខការ ។

មាត្រា ១០៨ : ទិដ្ឋាការចុះកិច្ចសន្យានៃចំណាយជាប្រក្រតី ក្រៅពីចំណាយបុគ្គលិក មិនអាចធ្វើអន្តរាគមន៍ក្រោម ថ្ងៃទី ១០ វិច្ឆិកា នៃឆ្នាំនីមួយៗបានទេ លើកលែងតែមានភាពប្រញាប់ ។

មាត្រា ១០៩ : ការសន្យាដែលអាណត្តិបើកប្រាក់មិនបានប្រតិបត្តិការនៅថ្ងៃទី ៣១ ធ្នូ ត្រូវបានកត់ត្រាជាបន្តចូលក្នុងឥណទាននៃថវិកានៃឆ្នាំបន្ទាប់ ។

មាត្រា ១១០ : ចាប់ពីថ្ងៃទី ០១ ធ្នូ នៃឆ្នាំនីមួយៗនិងក្នុងកំរិតមួយភាគដប់ពីរ នៃឥណទានប្រចាំឆ្នាំកំពុងប្រព្រឹត្ត ការសន្យាចំណាយជាប្រក្រតី អាចធ្វើបានក្នុងករណីមានភាពប្រញាប់លើឥណទាននៃឆ្នាំបន្ទាប់ ។ ការសន្យានេះចែងថា ការប្រតិបត្តិនៃសោហ៊ុយមិនអាចធ្វើអន្តរាគមន៍បានមុនថ្ងៃទី ០១ មករា ទេ ។

មាត្រា ១១១ : រហូតដល់ថ្ងៃ ២៨ ខែ កុម្ភៈ ប្រតិបត្តិការនិយ័តកម្ម ត្រូវបានពិនិត្យកត់ត្រាជាលេខនាបន្ថែមនៅ ថ្ងៃទី ៣១ ធ្នូ ។ ប្រតិបត្តិការនិយ័តកម្មទាក់ទងដល់ :

-ការកត់ត្រាជាស្ថាពរនៃចំណូល ឬ នៃចំណាយ ដែលបានពិនិត្យកត់ត្រាជាលេខនាថ្ងៃទី ៣១ ធ្នូ ជាអាទិ៍ចូលគណនីកត់ត្រាបណ្តោះអាសន្ន ។

-អាណត្តិនិយតកម្ម ដែលទាក់ទងផលចំណាយដែលបានទូទាត់ដោយវិធីទេយ្យករបុរេប្រទាន មុនថ្ងៃទី ៣១ ធ្នូ ។

-ការកែប្រែលេខនាខុស ។

-ប្រតិបត្តិការប្រមូលកិច្ចការគណនេយ្យនៃអង្គការរដ្ឋបាលហិរញ្ញវត្ថុ និង គណនេយ្យរងនៃរតនាគារខេត្ត-ក្រុង ។

ជំពូកទី ៥

លទ្ធផលប្រចាំឆ្នាំ និង គណនីចុងឆ្នាំ

មាត្រា ១១២ : គណនីលទ្ធផលពិពណ៌នាអំពីសំណុំលើស និង ខិនភាពដែលរដ្ឋសម្រេចបានក្នុងអំឡុងការគ្រប់គ្រងនីមួយៗ ។ ដោយហេតុនេះត្រូវកត់ត្រាចូលគណនីលទ្ធផលគឺ សមតុល្យនៃចំណូល និង ចំណាយថវិកាទូទៅ និង លើស ឬ ខិនភាពដែល ពិនិត្យឃើញអនុលោមតាមបទបញ្ញត្តិនៃច្បាប់ប្រព័ន្ធ ហិរញ្ញវត្ថុដែលទាក់ ទងផលច្បាប់ហិរញ្ញវត្ថុក្នុងការប្រតិបត្តិគណនីពិសេសទាំងឡាយរបស់រតនាគារ និង ប្រតិបត្តិការរតនៈវត្ថុ ។

មាត្រា ១១៣ : គណនីទាំងឡាយរបស់រដ្ឋត្រូវបាន (រៀបចំ) ធ្វើឡើងរាល់ឆ្នាំដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គណនីទូទៅនៃការគ្រប់គ្រងរដ្ឋបាលហិរញ្ញវត្ថុមាន ៖

-តុល្យភាពទូទៅ នៃគណនីដែលបានសំយោគគណនីរបស់គណនេយ្យករសាធារណៈ

- អត្ថាធិប្បាយអំពីចំណូលថវិកា

-អត្ថាធិប្បាយអំពី ចំណាយថវិកាដែលបង្ហាញសំរាប់ក្រសួងនីមួយៗ នូវចំនួនទឹកប្រាក់ ចំណាយតាមជំពូកដែលបញ្ជាក់ដោយរដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ

–អត្ថាធិប្បាយអំពី ប្រតិបត្តិការដែលបានពិនិត្យឃើញក្នុងគណនី ពិសេសរបស់រតនាគារ

–អត្ថាធិប្បាយពីគណនីលទ្ធផល

មាត្រា ១១៤ : រាល់ឆ្នាំរដ្ឋមន្ត្រីនីមួយៗធ្វើរបាយការណ៍គ្រប់គ្រង និង បញ្ជាក់សមិទ្ធភាពដែលមានរវាងលេខនារបស់សាមីក្រសួង និង អត្ថាធិប្បាយអំពីចំណាយរបស់ក្រសួងនោះ ដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានផ្ញើជូន ។

មាត្រា ១១៥ : គណនីគ្រប់គ្រងរបស់គណនេយ្យករ ត្រូវបានផ្ញើជូនរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែល ដាក់អោយអធិការកិច្ចហិរញ្ញវត្ថុ ពិនិត្យមុនថ្ងៃទី ៣០ ខែ មិថុនា នៃឆ្នាំបន្ទាប់ ។

មាត្រា ១១៦ : សភាជាតិអនុម័តគណនីទាំងនោះ ហើយទូទាត់ថវិការដ្ឋជាស្ថាពរ ។
សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិការដ្ឋ ត្រូវបានដាក់ជូនសភា ជាតិមុនដំណាច់ឆ្នាំ ។ សេចក្តីព្រាងច្បាប់នេះផ្អែកលើគណនីទូទៅនៃការគ្រប់គ្រងរដ្ឋបាលហិរញ្ញវត្ថុ និង លើរបាយការណ៍គ្រប់ គ្រងទាំងឡាយដែលរៀបចំដោយរដ្ឋមន្ត្រីក្រសួងនានា និង លើសេចក្តីប្រកាសទូទៅ អំពីស មិទ្ធភាពដែលមានចែងក្នុងមាត្រា ១២២ ។

ភាគ V

ការត្រួតពិនិត្យ

ជំពូកទី ១

ការត្រួតពិនិត្យការគ្រប់គ្រងរបស់អាណាប័ក

មាត្រា ១១៧ : ការត្រួតពិនិត្យលើការគ្រប់គ្រងរបស់អាណាប័ក ត្រូវបានធានាដោយរដ្ឋសភា អង្គការ និង គណៈកម្មការត្រួតពិនិត្យដែលមានសមត្ថកិច្ច និង ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មាត្រា ១១៨ : រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធ្វើការត្រួតពិនិត្យដែលបានគ្រោងទុកក្នុងមាត្រាមុនតាម រយៈអធិការកិច្ចហិរញ្ញវត្ថុ និង អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ។

មាត្រា ១១៩ : រដ្ឋមន្ត្រីទាំងឡាយធ្វើការត្រួតពិនិត្យកិច្ចប្រតិបត្តិទាំងឡាយរបស់អាណាប័ក ក្រោមឱវាទ ដោយពិធី ត្រួតពិនិត្យដោយផ្ទាល់ ឬ តាមរយៈក្រុមត្រួតពិនិត្យ ។

មាត្រា ១២០ : គណនេយ្យកររដ្ឋធ្វើការត្រួតពិនិត្យលើប្រតិបត្តិការរបស់អាណាប័ក ដូចមានចែងក្នុងមាត្រា ១៣ ខាងលើ ។

ជំពូកទី ២

ការត្រួតពិនិត្យការគ្រប់គ្រងរបស់គណនេយ្យករ

មាត្រា ១២១ : ការត្រួតពិនិត្យការគ្រប់គ្រងរបស់គណនេយ្យករ ត្រូវបានធានាក្រោមអំណាចរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដោយឋានានុក្រមថ្នាក់លើរបស់គណនេយ្យករ និង ដោយអធិការកិច្ចហិរញ្ញវត្ថុ ។

ភាគ VI

អន្តរប្បញ្ញត្តិ និង អវសានបញ្ញត្តិ

មាត្រា ១២២ : គោលការណ៍ចម្បងទាំងឡាយស្តីពីកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និង គណនេយ្យ ដែលជាលទ្ធផល នៃការប្រតិបត្តិថវិការដ្ឋអាចអនុវត្តក្នុងកិច្ចប្រតិបត្តិការសមូហភាពមូលដ្ឋាន និង គ្រឹះស្ថានសាធារណៈទាំងឡាយចំពោះការប្រតិបត្តិថវិការបស់ខ្លួន ។

លក្ខណៈនៃគោលការណ៍ចម្បងក្នុងន័យវាក្យខណ្ឌខាងលើនេះ គឺគោលការណ៍ទាំងឡាយដែល បានចែងក្នុងមាត្រា ៣,៤ ពី ៨ ទៅ ១៧. ពី ២៣ ទៅ ៣១. ពី ៤៥ ទៅ ៤៨,៥១,៥៣ពី ៥៧ ទៅ ៥៩ ,៦២,៦៣, ពី ៦៨ ទៅ ៧១. ពី ៨៦ ទៅ ៨៨. ពី ៩៤ ទៅ ៩៩,១០៥,១១៨, និង ១២១ នៃអនុក្រឹត្យនេះ ។

មាត្រា ១២៣ : នីតិវិធីទាក់ទងដល់ប្រតិបត្តិការចំណាយថវិកាដែលបង្កើតដោយអនុក្រឹត្យនេះនឹងចូលជាធរមានជាជំហានៗ ។

ប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងកំណត់ចំពោះក្រសួង ខេត្ត ឬ ក្រុង នីមួយៗនូវកាលបរិច្ឆេទចូលជាធរមាននៃបទបញ្ញាថ្មី ។

មាត្រា ១២៤ : រាល់បទបញ្ញត្តិដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១២៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន អភិបាលគ្រប់ខេត្ត–ក្រុង និង គ្រប់អាណាប័កដើមខ្សែ ឬ អាណាប័កតាមការប្រទានសិទ្ធិ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៨៣ អ.ន.ក្រ.បក

ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រ កម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤– ៨៣ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត. ១០៩៤– ៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- ផ្អែកតាមអនុសញ្ញា ស្តីពីសិទ្ធិរបស់កុមារ ដែលក្រុមប្រឹក្សាជាតិជាន់ខ្ពស់ បានចុះហត្ថលេខានៅថ្ងៃ ទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩២ និង បានផ្តល់សច្ចាប័ន នៅថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៣
- យោងសេចក្តីថ្លែងការជាន់ខ្ពស់ជាសកល ដើម្បីកុមារដែលព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** បានឡាយព្រះហស្តលេខា នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៣
- យោងលិខិតលេខ ១០១៥ សជណ.អវ.របស់ទីស្តីការគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងកុមារកម្ពុជា

សម្រេច

មាត្រា ១ : បង្កើតក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ ហៅកាត់ « ក.ជ.ក.ក. » ក្នុងបំណងធានាកិច្ចសហការ សំរបសំរួលដ៏សមស្របក្នុងការអនុវត្តន៍ ការតាមដានត្រួតពិនិត្យ និងវាយតំលៃលើគោលនយោបាយទាំងឡាយ និង កម្មវិធីដែលទាក់ទងទៅនឹងការរស់រានមានជីវិត ការអភិវឌ្ឍន៍ ការការពារ ការលើកកំពស់សុខមាលភាព និងការចូលរួមចំណែករបស់កុមារកម្ពុជា ។

មាត្រា ២ : សមាសភាព « ក.ជ.ក.ក » រួមមាន ÷

១– សម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី ១ និង សម្តេចនាយករដ្ឋមន្ត្រីទី ២		ជាសហប្រធានកិត្តិយស
២– ឯកឧត្តម រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន		ជាប្រធាន
៣– តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	១ រូប	ជាអនុប្រធាន
៤– តំណាងក្រសួងមហាផ្ទៃ	១ រូប	ជាអនុប្រធាន
៥– តំណាងក្រសួងអប់រំយុវជន និងកីឡា	១ រូប	ជាអនុប្រធាន

៦– តំណាងក្រសួងសុខាភិបាល	១ រូប	ជាអនុប្រធាន
៧– តំណាងរដ្ឋលេខាធិការដ្ឋានកិច្ចការនារី	១ រូប	ជាអនុប្រធាន
៨– តំណាងរដ្ឋមន្ត្រីទទួលបន្ទុកមជ្ឈមណ្ឌលយុវនិតិសម្បទា	១ រូប	ជាសមាជិក
៩– តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	១ រូប	ជាសមាជិក
១០– តំណាងក្រសួងផែនការ	១ រូប	ជាសមាជិក
១១– តំណាងក្រសួងយុត្តិធម៌	១ រូប	ជាសមាជិក
១២– តំណាងក្រសួងពត៌មាន	១ រូប	ជាសមាជិក
១៣– តំណាងក្រសួងធម្មការ និង សាសនា	១ រូប	ជាសមាជិក
១៤– តំណាងក្រសួងអភិវឌ្ឍន៍ជនបទ	១ រូប	ជាសមាជិក
១៥– តំណាងកាកបាទក្រហមកម្ពុជា	១ រូប	ជាសមាជិក

មាត្រា ៣ : តំណាងភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ តំណាង វិជ្ជាស្ថានស្រាវជ្រាវ ពាក់ព័ន្ធក្នុងស្រុក អង្គការផ្តល់ជំនួយទ្វេភាគី អាចចូលជាសមាជិកសង្កេតការណ៍ ហើយអាចចូលរួមប្រជុំតាមការអញ្ជើញរបស់ « ក.ជ.ក.ក » ។

មាត្រា ៤ : « ក.ជ.ក.ក » មានភារកិច្ចដូចតទៅ ÷

– ជាស្ថាប័នថ្នាក់ជាតិ សំរាប់ការងារពិគ្រោះយោបល់ សំរបសំរួលសកម្មភាពទាំងឡាយ ដែលពាក់ព័ន្ធនឹងបញ្ហាកុមារនៅក្នុងប្រទេសកម្ពុជា ។

– ជួយរាជរដ្ឋាភិបាលក្នុងការតាមដាន និងធ្វើរបាយការណ៍លើបញ្ហាទាំងឡាយដែលពាក់ព័ន្ធ នឹងកុមារជួយដូចជាអនុសញ្ញាស្តីពីសិទ្ធិរបស់កុមារ និង កម្មវិធីសកម្មភាពជាតិសំរាប់កុមារ ។

– ស្រាវជ្រាវ និងជូនពត៌មាន ស្តីពីសេចក្តីត្រូវការ និង បញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងកុមារកម្ពុជាទៅរាជរដ្ឋាភិបាល ស្ថាប័ន និងអង្គការនានាដែលមានសមត្ថកិច្ច ។

– ទំនាក់ទំនងជាមួយសហគមន៍ជាតិ និងអន្តរជាតិដែលមានការងារប្រហាក់ប្រហែលគ្នា ដើម្បីប្តូរយោបល់បទពិសោធន៍ និងទស្សនៈរីកចំរើន ដែលទាក់ទងនឹងរយៈកាលវែងរួមក្នុងការកែលំអស្ថានភាពរបស់កុមារ ។

មាត្រា ៥ : « គ.ជ.ក.ក » មានរចនាសម្ព័ន្ធចាត់តាំង ដើម្បីដំណើរការដូចខាងក្រោម ៖

- មានអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ការិយាល័យមួយចំនួន សំរាប់បំរើការងារដែលមានទីតាំងនៅក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន ។
- អាចបង្កើតអនុគណៈកម្មការជំនាញ ដើម្បីធ្វើការងារមួយរយៈពេលតាមការកំណត់ ។
- មានគណៈកម្មការទីប្រឹក្សាមួយ ដែលមានសមាសភាពជាអ្នកជំនាញ ដើម្បីជួយ «គ.ជ.ក.ក» និងអគ្គលេខាធិការដ្ឋាន ។

មាត្រា ៦ : អគ្គលេខាធិការដ្ឋាន ប្រើប្រាស់បុគ្គលិកពីក្រសួងពាក់ព័ន្ធ ហើយចំនួនបុគ្គលិកកំណត់ដោយ «គ.ជ.ក.ក» ។

មាត្រា ៧ : តួនាទីភារកិច្ចរចនាសម្ព័ន្ធ និង ការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋាន ការិយាល័យអនុគណៈកម្មការ និង គណៈកម្មការទីប្រឹក្សាអាស្រ័យដោយ «គ.ជ.ក.ក» ជាអ្នកកំណត់សំរេច ។

មាត្រា ៨ : ថវិការបស់ «គ.ជ.ក.ក» ជាថវិកាមួយដោយឡែក ហើយជាឧបសម្ព័ន្ធថវិការបស់ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន ។

មាត្រា ៩ : «គ.ជ.ក.ក» មានបទបញ្ជាផ្ទៃក្នុង និង ត្រាមួយដោយឡែករបស់ខ្លួន ។

មាត្រា១០ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា១១ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងស្ថាប័នពាក់ព័ន្ធនានា ព្រមទាំង «គ.ជ.ក.ក» មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៩

អនុក្រឹត្យលេខ ១១៩ អនក្រ.

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណូមពរការងារចាំបាច់

សំរេច

មាត្រា ១ : ត្រូវបានតែងតាំងក្រុមជំនួយការផ្ទាល់ របស់មេធាវីរាជរដ្ឋាភិបាល នូវឥស្សរជនដូចមានរាយនាមខាងក្រោម ៖

១- លោក **ឆិល ចន្ទតារា**

២- លោក **គឹម យឿន**

មានឋានៈនិងបុព្វសិទ្ធិ ស្មើនឹងប្រធាននាយកដ្ឋាន

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី មេធាវីរាជរដ្ឋាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ១២០ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ. ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និង ប្រើប្រាស់មេដាយស្ថាបនាជាតិ និង បណ្ណស្ថាបនាជាតិ
- តាមសំណើរបស់សាលាក្រុងភ្នំពេញ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ ចំពោះសប្បុរសជន និង ក្រុមហ៊ុនចំនួន ១៤ ដែលបានឧបត្ថម្ភ ថវិការបស់ខ្លួនដើម្បីរួមចំណែកកែលំអរាជធានីភ្នំពេញក្នុងការស្ថាបនាសួនច្បារថ្មី ដីបួមមាត់ទន្លេ (សួនច្បារសម្តេចនាយករដ្ឋមន្ត្រីទី ២) ដូចមានរាយនាមខាងក្រោម ÷

ក/- មេដាយស្ថាបនាជាតិថ្នាក់លេខ ១ ចំពោះ ÷

១- ក្រុមហ៊ុន ហូលីដេ អាំងទែណាស្យូណាល់អូតែល		១០០.០០០ ដុល្លារ
២- លោកស្រី ឈុន លាង	ប្រធានក្រុមហ៊ុន វឌ្ឍនៈ	២០.០០០ ដុល្លារ
៣- លោកស្រី លីម ស៊ីណា	ប្រធានរោងចក្រទឹកកក	១០.០០០ ដុល្លារ
៤- លោក ឧកញ៉ា សុខ គង់	ប្រធានក្រុមហ៊ុន សូគីមិច	២០.០០០ ដុល្លារ

៥– លោក ឧកញ៉ា ថេង ប៊ុនម៉ា ក្រុមហ៊ុនថៃប៊ុនរ៉ុង ៥០.០០០ ដុល្លារ

៦– លោក តៅ ខុនផាក ១០.០០០ ដុល្លារ

៧– លោក ដាតូជែន ប្រធានក្រុមហ៊ុន ណាហ្គា ៥០.០០០ ដុល្លារ

៨– លោក ឧកញ៉ា គីមហាប់ ប្រធានក្រុមហ៊ុន គីមហេប ២០.០០០ ដុល្លារ

៩– លោក ឧកញ៉ា កុក អាន ប្រធានក្រុមហ៊ុន អានកូ ២០.០០០ ដុល្លារ

១០– លោក គីម ឈាន ប្រធានក្រុមហ៊ុន គ.ឈ. ហ្សេស៊ីន ២២.៦០៨ ដុល្លារ

១១– លោក ឧកញ៉ា គង់ ទ្រីវ ប្រធានក្រុមហ៊ុន ថ្នាំជក់កម្ពុជា ២០.០០០ ដុល្លារ

១២– លោក ម៉េង សេង ក្រុមហ៊ុន សៅរ៉ាតាន ១០.០០០ ដុល្លារ

១៣– លោក ម៉ាត់ ការ៉ុន ក្រុមហ៊ុន សៅរ៉ាតាន ២០.០០០ ដុល្លារ

ខ/– មេដាយស្ថាបនាជាតិថ្នាក់លេខ ៣

ចំពោះលោកប្រធានក្រុមហ៊ុនវីពេកាហុងកុង ដែលបានឧបត្ថម្ភប្រាក់ ១.០០០ ដុល្លារ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រតិភូរាជរដ្ឋាភិបាល ប្រចាំរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ១២១ អនក្រ.តត

ស្តីពីការផ្ទេរក្របខណ្ឌមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រ កម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤/៨៣ ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤ /៩៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- យោងមាត្រា ៦៣ ជំពូកទី ១០ នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលដែលប្រកាសអោយ ប្រើដោយព្រះរាជក្រមលេខ ០៦ នស.៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន
- តាមយោបល់ឯកភាពរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សំរេច

មាត្រា ១ : យល់ព្រមពន្យារពេលចូលនិវត្តន៍ចំនួន ០១ឆ្នាំតទៅទៀតសំរាប់លោក **អ៊ុក ចំនួ** ប្រធានក្រុមហ៊ុន ស្ពានថ្នល់ផ្លូវគោក នៃក្រសួងសាធារណការ និង ដឹកជញ្ជូនដោយគិតចាប់ពីថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩៥ ដល់ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩៦ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈព្រមទាំងលោក **អ៊ុក ចំនួ** ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ១២២ អនក្រ.តត

ស្តីពីការពន្យារពេលចូលនិវត្តន៍មន្ត្រីរាជការរាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រ កម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- យោងមាត្រា ៦៣ ជំពូកទី ១០ នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលដែលប្រកាសអោយ ប្រើដោយព្រះរាជក្រមលេខ ០៦ នស.៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
- តាមយោបល់ឯកភាពរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សំរេច

មាត្រា ១ : យល់ព្រមពន្យារពេលចូលនិវត្តន៍ ០១ ឆ្នាំតទៅទៀតជូនលោក **កែប សុខណៃ** ប្រធានមន្ទីរផែ ក្រសួងពាណិជ្ជកម្ម ដោយគិតចាប់ពីថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ដល់ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ។

មាត្រា ៣ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការ ជាន់មុខការសាធារណៈព្រមទាំង ... ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃទីឡាយព្រះហស្តលេខា និងចុះហត្ថលេខា តទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

នរោត្តម រណឫទ្ធិ ហ៊ុន សែន

២—សេចក្តីសម្រេច

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

សេចក្តីសម្រេចលេខ ៧៨ សសរ
ស្តីពីការប្រគល់ភារកិច្ចបណ្តោះអាសន្ន

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- ផ្អែកតាមការចាំបាច់

សម្រេច

ប្រការ ១ : ប្រគល់ភារកិច្ចជូនឯកឧត្តម ស៊ុំ ម៉ាន់អ៊ិត រដ្ឋលេខាធិការទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីជារដ្ឋមន្ត្រីស្តីទីក្រសួងផែនការ ចាប់ពីថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៥ រហូតដល់ថ្ងៃឯកឧត្តម ជា ចាន់តូ ត្រឡប់មកពីបំពេញបេសកកម្មនៅឯបរទេស ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តម ដែលមាន

ឈ្មោះក្នុងប្រការ ១ ត្រូវទទួលអនុវត្តសេចក្តីសំរេច ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ៧៩ សសរ
ស្តីពីការប្រគល់ភារកិច្ចបណ្តោះអាសន្ន

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- ផ្អែកតាមការចាំបាច់

សំរេច

ប្រការ ១ : ប្រគល់ភារកិច្ចជូនឯកឧត្តម **យូ ហុកគ្រី** សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជារដ្ឋមន្ត្រីស្តីទីក្រសួងសាធារណការ និង ដឹកជញ្ជូន ចាប់ពីថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ រហូតដល់ថ្ងៃឯកឧត្តមឧបនាយក រដ្ឋមន្ត្រី **អ៊ុង ហ្វឿត** ត្រឡប់មកពីបំពេញបេសកកម្មនៅទីក្រុងបាងកកប្រទេសថៃ ទីក្រុងហូជីមិញប្រទេសវៀតណាម និង ប្រទេសសិង្ហបុរីវិញ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការអនុរដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តម **យូ ហុកគ្រី**

ត្រូវទទួលអនុវត្តសេចក្តីសំរេច ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខា តទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខា និង ត្រា ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ ហ៊ុន សែន

* * *

II- ការងារបណ្តាក្រសួង

១– ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាសលេខ ២០៤ សហវ.ប្រក.ប

ស្តីពីការដាក់ឯកឧត្តម ជាវ ឡាយ ជាអតីត

អនុរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចូលនិវត្តន៍

* * *

ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស.រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការ កែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញលិខិតលេខ ២៩០ សជណ.ផក ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ១៩៩៣ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការរៀបចំក្រៅក្របខ័ណ្ឌឯកឧត្តម អតីតរដ្ឋមន្ត្រី និងអនុរដ្ឋមន្ត្រីក្រៅតំណែង

-បានឃើញលិខិតលេខ ១៣៧៤ សជណ.ពហ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីរាជរដ្ឋាភិបាលបានឯកភាពអោយឯកឧត្តម ខាង ឡាង អតីតអនុរដ្ឋមន្ត្រីក្រៅតំណែង នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុចូលនិវត្តន៍

សម្រេច

មាត្រា ១ : ត្រូវបានដាក់ឯកឧត្តម ខាង ឡាង អតីតអនុរដ្ឋមន្ត្រីក្រៅតំណែង នៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ « ថារាងកាំបៀវត្ស ១.៥ » ចូលនិវត្តន៍គិតចាប់ពីថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៥ នេះតទៅ ។

មាត្រា ២ : ដើម្បីមានសិទ្ធិទទួលរបបប្រាក់សោធននិវត្តន៍ និង ប្រាក់ឧបត្ថម្ភលើកដំបូងម្តងគត់បាន សាមីខ្លួនត្រូវបំពេញបែបបទសំណុំលិខិតចូលនិវត្តន៍តាមល័ក្ខខ័ណ្ឌ ដែលមានចែងក្នុងច្បាប់ជាធរមាន ។

-ប្រសិនបើហួសកាលបរិច្ឆេទកំណត់ដូចមានចែងក្នុងមាត្រា ១ ខាងលើ ក្រសួងនឹងលុបឈ្មោះចេញពីក្របខ័ណ្ឌរដ្ឋដោយស្វ័យប្រវត្តិ ។

មាត្រា ៣ : នាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក និង អង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ត្រូវអនុវត្តតាមភារកិច្ចរៀង ៗ ខ្លួន នូវប្រកាសនេះ ។

ហត្ថលេខានិងត្រា

គាត ឈន់

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៣៤៧ ប្រក សហវ.ថ

ស្តីពីការបែងចែកឥណទាន

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិង ការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការ កែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ ០១ នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីការកែតំរូវនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាស អោយប្រើដោយព្រះរាជក្រម នស/រកម/០៩៩៥/០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ៧៥ អនក្រ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីអំពីការបែងចែកឥណទានតាមជំពូក នៃច្បាប់ស្តីពីការកែតំរូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុលេខ ៣៣៨ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទានផ្ទៃក្នុងតាមជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ជូនបណ្តាក្រសួងតាមឥណទានចែងក្នុងច្បាប់ ស្តីពីការកែតំរូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុលេខ ០០៦ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការណែនាំអនុវត្តថវិកា ឆ្នាំ ១៩៩៥
- តាមសំណើរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ ៩៨២ លស.ផហ ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៩៥

សម្រេច

ប្រការ ១ : ត្រូវបានប្រតិបត្តិនៅក្នុងវង្គថវិកា របស់ទីស្ដីការគណៈរដ្ឋមន្ត្រីសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ នូវការបង្វែរឥណទានដូចបានបញ្ជាក់ខាងក្រោមនេះ :

ឯកត្តា: ពាន់រៀល

ជំពូក	ប្រការ	កថាខណ្ឌ	វាក្យខណ្ឌ	ចំណាត់ថ្នាក់ចំណាយ	ឥណទានកែតម្រូវ	ការកែប្រែឥណទាន		ស្ថានភាពឥណទានថ្មី
						កើន	ថយ	
				ការបង្វែរពីជំពូក ១១			280.000	
11	01	14	04	ចំណាយពិសេសរបស រាជរដ្ឋាភិបាល	6.500.000		280.000	6.220.000
				ផលប្រយោជន៍ជំពូក ១១		280.000		
11	01	03		សោហ៊ុយគមនាគមន៍ ទូរស័ព្ទគេឡិច ទូរសារ ប្រៃសណីយ៍	500.000	200.000		700.000
11	02	02	01	សោហ៊ុយដឹកជញ្ជូនក្រៅប្រទេស	600.000	80.000		680.000

ប្រការ ២ : ឯកឧត្ដមសហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ជាអ្នកទទួលបន្ទុកការ អនុវត្តន៍ប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

អនុរដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

នាយ ថន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាស

លេខ ៣៨៩ ប្រក សហវ.ថ

ស្ដីអំពីការបង្វែរឥណទាន

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម **សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការ កែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីអំពីការកែតំរូវនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាស អោយប្រើដោយព្រះរាជក្រម ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ៧៥ អនក្រ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីអំពីការបែងចែកឥណទានតាមជំពូក នៃច្បាប់ស្តីអំពីការកែតំរូវនៃច្បាប់ហិរញ្ញវត្ថុសំរាបការគ្រប់ គ្រង ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុលេខ ៣៣៨ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទានផ្ទៃក្នុងតាមជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌជូនបណ្តាក្រសួងតាមឥណទានចែងក្នុងច្បាប់ស្តីអំពីការកែតំរូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុលេខ ០០៦ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការណែនាំអនុវត្តថវិកា ឆ្នាំ ១៩៩៥
- តាមសំណើរបស់ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជនលេខ ១២០៨ ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៩៩៥

សម្រេច

ប្រការ ១ : ត្រូវបានប្រតិបត្តិនៅក្នុងរង្វង់ថវិកា របស់ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជនសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ នូវការបង្វែរឥណទានដូចបានបញ្ជាក់ខាងក្រោមនេះ :

ជំពូក	ប្រការ	កថាខណ្ឌ	វាក្យខណ្ឌ	ចំណាត់ថ្នាក់ចំណាយ	ឥណទានដែលកំណត់	ការកែប្រែឥណទាន		ស្ថានភាពឥណទានថ្មី
						កើន	ថយ	
				បង្វែរពីជំពូក ៣១				
31	01	01	01	សម្រាលកូន	2.700.000	1.000.000		1.700.000
31	01	01	02	ឧបត្ថម្ភមន្ត្រីរាជការមានជំងឺ	5.800.000	1.000.000		4.800.000
31	01	01	03	គ្រោះថ្នាក់ក្នុងការងារ	5.000.000	2.000.000		3.000.000
31	01	01	04	មរណភាព	3.500.000	2.000.000		1.500.000
31	01	01	10	ឧបត្ថម្ភនិវត្តជន	7.100.000	6.000.000		1.100.000
31	02	02		ឧបត្ថម្ភមណ្ឌលកុមារកំព្រា	81.700.000	4.000.000		77.700.000
				ផលប្រយោជន៍ជំពូក ៣១				
31	01	01	05	ទុព្វលភាព	29.600.000		16.000.000	45.600.000

ប្រការ ២ : ឯកឧត្តមរដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន ជាអ្នកទទួលបន្ទុកការអនុវត្តន៍ប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

អនុរដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ឆាយ ចន

* * *

២—ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សេចក្ដីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

សេចក្ដីសំរេច

លេខ ២៧៦/៩៥ ពម.សសរ

ស្ដីពីការបង្កើតគណៈកម្មការសាងសង់

- បានឃើញព្រះរាជក្រឹត្យព្រះករុណា ព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញសេចក្ដីសំរេចលេខ ១៨៩–៩៥ ពម.សសរ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៥ របស់ក្រសួងពាណិជ្ជកម្ម
- ពិនិត្យលើសំណូមពរ និង ភារកិច្ចរបស់ក្រសួង
- ពិនិត្យលើសមត្ថភាពរបស់ថ្នាក់ដឹកនាំ និង មន្ត្រីរាជការ

សំរេច

ប្រការ ១ : កែប្រែសមាសភាពគណៈកម្មការមួយសំរាប់ទទួលបន្ទុកការសាងសង់ផ្ទះមុខងារ ក្រសួងពាណិជ្ជកម្មរួមមាន សមាសភាពថ្មីដូចខាងក្រោមនេះ ÷

១–ឯកឧត្ដម	អ៊ុច	នាស៊ាង	ជាប្រធាន
២–លោក	សែន	សំណាង	ជាអនុប្រធាន
៣–លោក	សាន	សំបូរ	ជាសមាជិក
៤–លោក	សេង	ម៉ារ៉ាសែ	ជាសមាជិក
៥–លោក	ហ៊ុន	ផល្លុន	ជាសមាជិក
៦–លោក	សេះ	ម៉ុនធុល	ជាសមាជិក
៧–លោក	ញ៉ឹង	សម្បត្តិ	ជាសមាជិក

៨_លោក ឌុស សុវណ្ណ ជាសមាជិក

៩_លោក សេង ទីន ជាសមាជិក

ប្រការ ២ : គណៈកម្មការសាងសង់នេះមានភារកិច្ច ÷

–លើកគំរោងសាងសង់អោយបានច្បាស់លាស់ និងធ្វើការវេញថ្លៃតាមគោលការណ៍រដ្ឋ ។

–បែងចែកភារកិច្ចទទួលខុសត្រូវ និង គិតគូរស្នើថវិកា ។

–គិតគូរបញ្ជីចំណាយសមស្របតាមលក្ខការណ៍ ។

–បូកសរុប និង ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ ។

ប្រការ ៣ : អគ្គនាយកដ្ឋាន រដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គាធិការដ្ឋាន និង សាមីខ្លួនមានភារៈអនុវត្ត តាមសេចក្តីសំរេចអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាស

លេខ ២៧៨/៩៥ ពម.ប្រក

អនុញ្ញាតអោយលោក ឈឹម ចិន្តា បើក

អាជីវកម្មរោងពុម្ពឈ្មោះ « ទិចិត្រសិល្ប: »

រដ្ឋមន្ត្រីក្រសួងពត៌មាន

–បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ចុះថ្ងៃ... ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១_១១_១៩៩៣ ស្តីពីការ

តែងតាំងរាជរដ្ឋាភិបាល

_យោងលិខិតជូនដំណឹងរបស់ក្រសួងពត៌មានលេខ ១២២៤/៩៤ ពម ចុះថ្ងៃទី ១៤_១១_១៩៩៤ ស្តីពីការបោះពុម្ពផ្សាយ

_យោងលិខិតសំណើសុំអនុញ្ញាតច្បាប់បើកអាជីវកម្មរោងពុម្ពឈ្មោះ «វិចិត្រសិល្បៈ» របស់លោក **ឈឹស មិន្ឋា** ចុះថ្ងៃទី ៤ ខែ តុលា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : អនុញ្ញាតជូនលោក **ឈឹស មិន្ឋា** អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៣៦ អ៊ី.អូ វិថីកែវជា សង្កាត់ផ្សារថ្មី ២ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ បើកអាជីវកម្មរោងពុម្ពដែលមានឈ្មោះ « វិចិត្រសិល្បៈ » ស្ថិតនៅទីតាំងដូចលំនៅស្ថានខាងលើ ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពផ្សាយ ត្រូវអនុវត្តអោយបានល្អតាមកិច្ចសន្យាសមស្រប និងរក្សាអោយបាននូវទំនៀមទំលាប់ សន្តិសុខសណ្តាប់ធ្នាប់សង្គម និង ច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៣ : ក្នុងករណីប្រព្រឹត្តល្មើស ដូចមានចែងក្នុងប្រការ ២ សាមីជននឹងត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : នាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ _ សោតទស្សន៍ នៃ អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ និងប្រធានមន្ទីរពត៌មានរាជធានីភ្នំពេញ ត្រូវទទួលអនុវត្តសេចក្តីប្រកាសនេះតាម ភារកិច្ចរៀង ៗ ខ្លួន ។

ប្រការ ៥ : ប្រកាសនេះ មានអានុភាពអនុវត្តច្បាប់ ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាស

លេខ ២៧៩/៩៥ ពម.ប្រក

ស្តីពីការអនុញ្ញាតអោយបង្កើតស្ថានីយ៍ទូរទស្សន៍ប្រើខ្សែកាប

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ របស់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញលិខិតក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គណៈកម្មាធិការវិនិយោគ ចុះថ្ងៃទី ៣០ មិថុនា ១៩៩៤

សំរេច

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន KCS Cambodia Co. ដំណើរការស្ថានីយ៍ទូរទស្សន៍ប្រើខ្សែកាប (Cable TV) នៅក្នុងរាជធានីភ្នំពេញ ។

ប្រការ ២ : សេចក្ដីអនុញ្ញាតតាមប្រកាសនេះ មានប្រសិទ្ធភាពសំរាប់រយៈពេល ១០ ឆ្នាំ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ប្រការ៣ : ក្រុមហ៊ុន KCS Cambodia Co. ត្រូវទទួលខុសត្រូវទាំងស្រុងលើការផ្សាយព្រមទាំងគោរពច្បាប់ ទបញ្ញត្តិ បទបញ្ជា ឬ សេចក្ដីណែនាំខាងផ្នែកសោតទស្សន៍ទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៤ : អគ្គនាយកទូរទស្សន៍កម្ពុជា អគ្គនាយកហិរញ្ញវត្ថុនិងរដ្ឋបាល អគ្គាធិការក្រសួងពតិមាន និងបណ្ដាអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

រដ្ឋមន្ត្រី
ហត្ថលេខានិងត្រា
អៀង មូលី

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាស

លេខ ២៨០/៩៥ ពម.ប្រក

អនុញ្ញាតអោយទស្សនាវដ្ដី « ឆ្ពោះទៅមុខ »

ដំណើរការបោះពុម្ពផ្សាយ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា ពិពួកអវសានបញ្ញត្តិមាត្រាទី ១៣៩
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេច ព្រះ**នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ន.ស.រ.ក.ម ០៨៩៥_០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ប្រកាសអោយប្រើច្បាប់ស្តីពីរបបសារពត៌មាន នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញលិខិតរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការនារីលេខ ១៤៧៧ ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ស្នើសុំចេញផ្សាយទស្សនាវដ្តី « ឆ្ពោះទៅមុខ »

សំរេច

ប្រការ ១ : អនុញ្ញាតអោយទស្សនាវដ្តី « **ឆ្ពោះទៅមុខ** » បោះពុម្ពផ្សាយដោយមានអ្នកស្រី **ខូ ម៉ិនអេង** ជាចាងហ្វាងការផ្សាយ ។

ប្រការ ២ : ខ្លឹមសារអត្ថបទ និង សកម្មភាពផ្សព្វផ្សាយត្រូវសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អនិងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៣ : គោរពតាមគោលការណ៍ក្រមសីលធម៌អ្នកកាសែត និង ឈរលើស្មារតីទទួលខុសត្រូវខ្ពស់លើវិជ្ជាជីវៈរបស់ខ្លួន ព្រមទាំងស្នើប្រគល់ទស្សនាវដ្តីចំនួន ០៦ ច្បាប់រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៤ : អ្នកស្រី **ខូ ម៉ិនអេង** ចាងហ្វាងការផ្សាយទស្សនាវដ្តី « **ឆ្ពោះទៅមុខ** » និងនាយកដ្ឋានមណ្ឌលពត៌មាន នៃ ក្រសួងពត៌មាន ត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩៥

ប្រកាស

លេខ ២៨១/៩៥ ពម.ប្រក

អនុញ្ញាតអោយទស្សនាវដ្តី « សុវណ្ណមច្ឆា » ដំណើរការបោះពុម្ពផ្សាយ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា ជំពូកអវសានបញ្ញត្តិមាត្រាទី ១៣៩
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ន.ស.រ.ក.ម ០៨៩៥_០៧ ចុះថ្ងៃទី ០១ កញ្ញា ១៩៩៥ ប្រកាសអោយប្រើច្បាប់ស្តីពីរបបសារពតិមាន នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញសំណើសុំរបស់ **នាង សុក សុទ្ធី** ចុះថ្ងៃទី ១២ តុលា ១៩៩៥

សំរេច

ប្រការ ១ : អនុញ្ញាតអោយបោះពុម្ពផ្សាយទស្សនាវដ្តីឈ្មោះ «**សុវណ្ណមច្ឆា**» ដោយមាន**នាង សុក សុទ្ធី** ជាចាងហ្វាងការផ្សាយ ។

ប្រការ ២ : ខ្លឹមសារ អត្ថបទ និងសកម្មភាពផ្សព្វផ្សាយត្រូវអោយបានសមស្របតាមទំនៀមទម្លាប់ ប្រពៃណីល្អ និង ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៣ : គោរពតាមគោលការណ៍ក្រមសីលធម៌អ្នកកាសែត និងឈរលើស្មារតីទទួលខុសត្រូវខ្ពស់លើនាទីរបស់ខ្លួន ព្រមទាំងផ្ញើប្រគល់ទស្សនាវដ្តីចំនួន ០៦ ច្បាប់រៀងរាល់លេខចេញផ្សាយមកតំកល់ ទុកជាឯកសារនៅក្រសួងពតិមាន ។

ប្រការ ៤ : **នាង សុក សុទ្ធី** ជាចាងហ្វាងការផ្សាយ និងនាយកដ្ឋានមណ្ឌលពតិមាន នៃក្រសួង ពតិមានត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាស

លេខ ២៨២/៩៥ ពម.ប្រក

អនុញ្ញាតអោយទស្សនាវដ្តីឈ្មោះ « យុវជន »

ដំណើរការបោះពុម្ពផ្សាយ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា ពិសេសអវសានបញ្ញត្តិមាត្រាទី ១៣៩
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីរបបសារពត៌មានកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រកាសអោយប្រើតាមព្រះរាជក្រមលេខ ន.ស.រ.ក.ម ០៨៩៥_០៧ ចុះថ្ងៃទី ០១ កញ្ញា ១៩៩៥ ;
- បានឃើញសំណើសុំរបស់លោក អ៊ឹម សួស្តី អនុប្រធានសមាគមយុវជនកម្ពុជា ចុះថ្ងៃទី ២៥ តុលា ១៩៩៥

សំរេច

ប្រការ ១ : អនុញ្ញាតអោយបោះពុម្ពផ្សាយទស្សនាវដ្តីឈ្មោះ « **យុវជន** » ដោយមាន លោក **អ៊ឹម សួស្តី** ជាចាងហ្វាងការផ្សាយ ។

ប្រការ ២ : ខ្លឹមសារ អត្ថបទ និង សកម្មភាពផ្សព្វផ្សាយត្រូវអោយបានសមស្របតាមទំនៀមទម្លាប់ប្រពៃណីល្អ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៣ : គោរពតាមគោលការណ៍ក្រមសីលធម៌ អ្នកកាសែត និង ឈរលើស្មារតីទទួលខុសត្រូវខ្ពស់លើវិជ្ជាជីវៈរបស់ខ្លួន ព្រមទាំងស្នើប្រគល់ទស្សនាវដ្ដីចំនួន ០៦ ច្បាប់ រៀងរាល់លេខចេញផ្សាយ មកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៤ : លោក **អ៊ុំ សួស្ដី** ជាចាងហ្វាងការផ្សាយ និងនាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មានត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះមានប្រសិទ្ធភាពក្នុងរយៈពេល ៣ ឆ្នាំ និងចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាសលេខ ២៨៣/៩៥ ពម.ប្រក

អនុញ្ញាតអោយកាសែត « អង្គរថ្មី »

ដំណើរការបោះពុម្ពផ្សាយ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រាទី ៤១ ។
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះនរោត្ដម **សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស.រកម ០៨៩៥-៧០ ចុះថ្ងៃទី ០១ កញ្ញា ១៩៩៥ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីរបបសារពត៌មាន នៃព្រះរាជាណា ចក្រកម្ពុជា

- បានឃើញប្រកាសបិទកាសែត « អង្គរថ្មី » របស់ក្រសួងព័ត៌មាន លេខ ០៥៥–៩៤ ពម.សរ ចុះថ្ងៃទី ២៧–៧–១៩៩៥ ។
- បានឃើញពាក្យស្នើសុំចេញផ្សាយកាសែត « អង្គរថ្មី » ឡើងវិញ របស់លោក អ៊ុំ [illegible] ចុះថ្ងៃទី ១៥ តុលា ១៩៩៥ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយកាសែត « អង្គរថ្មី » បោះពុម្ពចេញផ្សាយឡើងវិញដោយមានលោក ស៊ុំ តារា ជាចាងហ្វាងការផ្សាយ ។

ប្រការ ២ : ខ្លឹមសារអត្ថបទ និង សកម្មភាពផ្សព្វផ្សាយ ត្រូវសមស្របតាមទំនៀមទម្លាប់ប្រពៃណីល្អ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : គោរពតាមគោលការណ៍ ក្រមសីលធម៌អ្នកកាសែត និង ឈរលើស្មារតីទទួលខុសត្រូវខ្ពស់លើវិជ្ជាជីវៈរបស់ខ្លួន ព្រមទាំងស្នើប្រគល់កាសែត ០៦ ច្បាប់រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងព័ត៌មាន ។

ប្រការ ៤ : លោក ស៊ុំ តារា ចាងហ្វាងការផ្សាយកាសែត « អង្គរថ្មី » និងនាយកដ្ឋានមណ្ឌលព័ត៌មាន នៃក្រសួងព័ត៌មាន ត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះមានប្រសិទ្ធភាពក្នុងរយៈពេល ៣ ឆ្នាំ និង ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
ខៀវ កាញារីទ្ធ

* * *

៣— ទីស្តីការរដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៧៦១ ប្រក.សក.ច

ស្តីពីការប្រគល់ភារកិច្ចបន្ថែមជូនឯកឧត្តម មាសភក្ត្រ កែមរីរ៉ាន

ឧបនាយករដ្ឋមន្ត្រី–រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១–១១–១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

– បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១–១០–១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ។

– បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៥/៧៤ ចុះថ្ងៃទី ២២–១០–១៩៩៥ ស្តីពីការតែងតាំងឯកឧត្តម មាសភក្ត្រ កែមរីរ៉ាន ជាអនុរដ្ឋលេខាធិការក្រសួងសាធារណការ និង ដឹកជញ្ជូន ។

– បានឃើញប្រកាសលេខ ២៦១ សណ.សកប ចុះថ្ងៃទី ០១–៧–១៩៩៥ ស្តីពីការប្រគល់ភារកិច្ចជូនឯកឧត្តម ជីន គីមឡេង អនុរដ្ឋលេខាធិការអោយគ្រប់គ្រងលើវិស័យ[illegible] ដឹកជញ្ជូនផ្លូវគោក–ផ្លូវទឹក ។

– [illegible] របស់ក្រសួង ។

សម្រេច

ប្រការ ១ : ប្រគល់ភារកិច្ចជូនឯកឧត្តម មាសសោភ័ណ្ឌ ខៃមីរ៉ាន អនុរដ្ឋលេខាធិការក្រសួងសាធារណការនិង ដឹកជញ្ជូន អោយទទួលបន្ទុកដឹកនាំអគ្គនាយកដ្ឋានទីស្តីការក្រសួង និង គ្រប់គ្រងជំនួសមុខក្រសួង លើវិស័យដឹកជញ្ជូន ។

គ្រប់ករណីដែលភារកិច្ចខាងលើ មានការទាក់ទងចំបងទៅលើនយោបាយជាក់ស្តែងរបស់រាជរដ្ឋាភិបាល ត្រូវមានការពិគ្រោះ ជាមួយឯកឧត្តមឧប នាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូនសិនមុននឹងសំរេច ។

ប្រការ ២ : ក្នុងវិស័យដឹកជញ្ជូន ឯកឧត្តម មាសសោភ័ណ្ឌ ខៃមីរ៉ាន អនុរដ្ឋលេខាធិការមានភារកិច្ចគ្រប់គ្រងណែនាំត្រួតពិនិត្យតាមខ្សែបណ្តោយ នូវគ្រប់អង្គភាព និងនាយកដ្ឋានចំណុះក្រសួងមាន ÷

- នាយកដ្ឋាន ដឹកជញ្ជូន
- នាយកដ្ឋាន ភ្នាក់ងារកម្ពុជានាវាចរណ៍ (កាំសាប)
- ក្រុមហ៊ុន ដឹកជញ្ជូនដោយរថយន្ត
- ក្រុមហ៊ុន ដឹកជញ្ជូនអ្នកដំណើរ
- ក្រុមហ៊ុន កាំគ្រង់ស៊ីប
- កំពង់ផែ ភ្នំពេញ
- កំពង់ផែ ក្រុងព្រះសីហនុ
- រោងជាងស្វ័យយានកម្ពុជា
- សាលាបង្រៀន បើកបររថយន្ត
- រោងចក្រផ្គុំសព្វរថយន្ត ៧ មករា

ប្រការ ៣ : បើមុខងារខាងលើនេះ ឯកឧត្តម មាសសោភ័ណ្ឌ ខៃមីរ៉ាន ត្រូវបានទទួលបន្ទុកគ្រប់គ្រងនិងដឹកនាំអគ្គនាយកដ្ឋាន ក្រសួងសាធារណការ និង ដឹកជញ្ជូន ។

ប្រការ ៤ : ត្រូវចាត់ទុកជានិរាករណ៍នូវប្រកាសលេខ ៤៦១ សសរ.សកនរ ចុះថ្ងៃទី ០១-០៧-១៩៩៩ ។

ប្រការ ៥ : ឯកឧត្តមអគ្គនាយក លោកនាយកខុទ្ទកាល័យ ត្រូវទទួលបន្ទុកអនុវត្តរៀងៗខ្លួន តាមខ្លឹមសារនៃសេចក្តីប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន
ហត្ថលេខា និង ត្រា
អ៊ឹង គៀត

* * *

៤—ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាសលេខ ២៨៥៦ អយក.ប្រក
ស្តីពីការប្តូរឈ្មោះវិទ្យាល័យ ៧ មករា ទៅជា
« វិទ្យាល័យសម្តេចម៉ែ » ស្ថិតនៅក្នុងក្រុមហ៊ុន
ចំការកៅស៊ូជុប ខេត្តកំពង់ចាម

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចនរោត្តម **សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

– បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ។

– បានឃើញក្រឹត្យ–ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ វិច្ឆិកា ១៩៨៦ ស្តីពីប្រព័ន្ធអប់រំ ចំណេះទូទៅ ។

–យោងលិខិតរបស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ លេខ ៦០០៧ កសក. ចុះថ្ងៃទី ៣០ កញ្ញា ១៩៩៥ ។

–តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ។

សម្រេច

ប្រការ ១ : អនុញ្ញាតអោយប្តូរឈ្មោះវិទ្យាល័យ ៧ មករា បច្ចុប្បន្ន ទៅជា « **វិទ្យាល័យ សម្តេចឪ** » ចាប់ពីបវេសនកាល ឆ្នាំសិក្សា ១៩៩៥–៩៦ តទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានទីស្តីការ ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋានបុគ្គលិកនិង ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ចនៃក្រសួងអប់រំ យុវជន និង កីឡា មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ហត្ថលេខា និង ត្រា

តុល ឡោះ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាសលេខ ២៨៥៧ អយក.ប្រក

ស្តីពីការពង្រីកអនុវិទ្យាល័យ អង្គរសោមទៅជា

« **វិទ្យាល័យ អង្គរសោម** » **ក្នុងស្រុកត្រាំកក់ ខេត្តតាកែវ**

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

–បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចនរោត្តម **សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

–បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២៦ កក្កដា ១៩៩៤ ។

–បានឃើញក្រឹត្យ–ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ វិច្ឆិកា ១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ។

–យោងលិខិតរបស់ប្រធានមន្ទីរអប់រំ យុវជន និង កីឡា លេខ ២៩៣៨ អយក.តម ចុះថ្ងៃទី ៥ កញ្ញា ១៩៩៥ ដោយមានយោបល់ឯកភាពពីអភិបាលខេត្តតាកែវ ។

–តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មធ្យមសិក្សា ។

សម្រេច

ប្រការ ១ : អនុញ្ញាតអោយពង្រីក អនុវិទ្យាល័យអង្គរបុរីទៅជា « **វិទ្យាល័យអង្គរបុរី** » ចាប់ពីឆ្នាំសិក្សា ១៩៩៥–៩៦ តទៅ នៅក្នុងស្រុកត្រាំកក់ ខេត្តតាកែវ ។

ប្រការ ២ : **វិទ្យាល័យអង្គរបុរី** ត្រូវដឹកដោយនាយកមួយរូប និង នាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ ទៀតមួយចំនួនតាមអង្គការលេខនៃវិទ្យាល័យ ។

ប្រការ ៣ : នាយក.នាយករងនៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ការកិច្ចរបស់នាយក.នាយករងនៃវិទ្យាល័យ ។

ប្រការ ៤ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និង មធ្យមសិក្សា ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និង កីឡា មានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

ហត្ថលេខា និង ត្រា

តុល ឡោះ

* * *

ង—និតិការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

ប្រកាស

ប្រកាសលេខ ៤២២ ឧក.ប្រក ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ស៊ឹម គឹមគី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជាកាន់អត្តសញ្ញាណប័ណ្ណលេខ ០០០៩៨៩ ស្វ.រ ចុះថ្ងៃទី ១១–១១–៨៥ អាស័យដ្ឋានបច្ចុប្បន្ន ភូមិវាលយន្ត ឃុំស្វាយរៀង ស្រុក ស្វាយរៀង ខេត្ត ស្វាយរៀង បើកដំណើរការរោងម៉ាស៊ីនផលិតទឹកកកដើម នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផល គ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៤២៣ ឧក.ប្រក ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **លី យាង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៦២០១៩ ភ.ព ចុះថ្ងៃទី ២៧–៣–៨៩ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១០៣ ភូមិដើមចន្ទ សង្កាត់ច្បារអំពៅ ២ ខណ្ឌមានជ័យរាជធានីភ្នំពេញ បន្តដំណើរការ រោងម៉ាស៊ីនផលិតទឹកកកដើម នៅ ក្នុងទីតាំងក្រុម ២ ភូមិស្រះកែវ ឃុំកំពង់ចាស់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផល គ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ

បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ: ៨២៤ ឧក.ប្រក ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **ឡឹក ឃៀង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៨២៨១៥ ស្ក.រ ចុះថ្ងៃទី ១៤–៣–៩៣ អាស័យដ្ឋានបច្ចុប្បន្ន ភូមិវាលយន្ត ឃុំស្វាយរៀង ស្រុកស្វាយរៀង ខេត្តស្វាយរៀង បើកដំណើរការរោងម៉ាស៊ីនផលិត ទឹកកកដើមនៅក្នុងទីតាំងដូចមានអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ផលិតផល គ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ: ៨២៥ ឧក.ប្រក ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ខេង ឡេង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១២៥៩៦៣ ភ.ព ចុះថ្ងៃទី ២៧.៥.១៩៨៥ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៣៨ អា ផ្លូវលេខ ១៧៣ ក្រុម ២៣ សង្កាត់អូឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ បើកដំណើរសហគ្រាសឧស្សាហកម្មតូចផលិតទឹកបរិសុទ្ធ អាស៊ីតិច សញ្ញា « ផ្កាឈូក » នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : អ្នកស្រី **ខេង ឡេង** ត្រូវបានអនុញ្ញាតអោយផលិតទឹកបរិសុទ្ធអាស៊ីតិច សញ្ញា «ផ្កាឈូក» ស្របតាមគំរូសញ្ញាសំគាល់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត

ល្មើសច្បាប់ ផលិតផល គ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្ករអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ: ៨២៦ ឧក.ប្រក ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ម៉េង សុគុណធនុឡ្សន៍** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ០៩៩៩២៤ ប.ជ ចុះថ្ងៃទី ២៧-១០-៩២ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១៦១ អា មហាវិថីព្រះនរោត្តម សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរការ ឧស្សាហកម្មតូចផលិតទឹកបរិសុទ្ធ សញ្ញា «ប៉ិនហ្គ៊ិន PENGUIN » នៅក្នុងទីតាំងដីឡូត៍លេខ ១៧ ស្ទួន ផ្លូវលេខ ៣០៦ សង្កាត់បឹងកេងកងទី ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

ប្រការ ២ : អ្នកស្រី **ម៉េង សុគុណធនុឡ្សន៍** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម នូវមុខផលិតផលទឹកបរិសុទ្ធ សញ្ញា « ប៉ិនហ្គ៊ិន PENGUIN » ស្របតាមគំរូសញ្ញាសំគាល់ ដែលបានតំកល់ទុកនៅក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្ករអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ: ៨២៧ ឧក.ប្រក ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **ឡាញ់ សោភ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៦៣៥៧២ ក.ណ ចុះថ្ងៃទី ០៧-៥-៨៩ អាស័យដ្ឋានបច្ចុប្បន្ន ភូមិប្រធាតុ ស្រុកកោះធំ ខេត្តកណ្តាល បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៣០ សេះ នៅក្នុងទីតាំងភូមិពោធិរាម្នា ឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល ។

ប្រការ ២ : លោក **ឡាញ់ ឆេង** ត្រូវបន្តដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបា[ន] កំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១អោយបានយ៉ាងតិចបំផុត ៦[៥] ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋា[ន] ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹ[ត្ត] ល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដ[ក] ហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ: ៨២៨ ឧក.ប្រក ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **សាន់ មិត្ត** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៦៨៩៧៥ ក.ណ ចុះថ្ងៃទី ២១–៥–៨៩ អាស័យដ្ឋានបច្ចុប្បន្ន ភូមិលេខ១ ឃុំ[illegible] ស្រុកកោះធំ ខេត្តកណ្ដាល បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក សាន់ មិត្ត ត្រូវបន្តដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបាន កំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដក ហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ: ៤២៩ ឧក.ប្រក ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ទឹម គីក** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៤៣៤៣៣៧ ក.ភ ចុះថ្ងៃទី ១៩-៧-៨៨ អាស័យដ្ឋានបច្ចុប្បន្ន ភូមិកាន់យួរ ឃុំមេលំ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង បើកដំណើរការសិប្បកម្មផលិតទឹកត្រីសញ្ញា « ត្រីក្អែក » នៅក្នុងទីតាំងភូមិ ៨ ឃុំខ្សាម ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ។

ប្រការ ២ : អ្នកស្រី **ទឹម គីក** ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលទឹកត្រីសញ្ញា «ត្រីក្អែក» ស្របតាមគំរូសញ្ញាសំគាល់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយះពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផល គ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ: ៤៣០ ឧក.ប្រក ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **លីម សេង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៤៤១៥៧ ភ.ព ចុះថ្ងៃទី ២២-០១-៨៤ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៦៧ អឺ១ ផ្លូវលេខ ៤៥៤ ខ័ណ្ឌចំការមន រាជធានីភ្នំពេញបន្តដំណើរការឡផលិតឥដ្ឋ-ក្បឿង នៅក្នុងទីតាំងភូមិអន្លុងក្ងាន សង្កាត់ឃ្មួញ ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយះពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ: ៤៣១ ឧក.ប្រក ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ម៉េង ម៉ៃ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២០៦២៦៥ ភ.ព ចុះថ្ងៃទី ២២-០៣-៨៩ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៤៨០ អឺ០ ផ្លូវលេខ ១២៨ ក្រុមទី ៤ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មកាត់ដេរ សំលៀកបំពាក់ នៅក្នុងទីតាំង ផ្ទះលេខ ៤៧៨ អឺ២-អឺ៣ ផ្លូវ ១២៨ ក្រុម៤ សង្កាត់មិត្តភាព ខណ្ឌ ៧ មករា រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ ឬ បង្ក អោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូត វិញដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ពូ សុធីរ

បោះពុម្ពនៅរោងពុម្ពទីស្ដីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ១១២០ រៀល